*٨/٤٩–٤٦/٧ عَلِيُّ بْنُ إِبْرَاهِيمَ، قَالَ: حَدَّثَنِي أَبِي، عَنِ الْحَسَنِ بْنِ مَحْبُوبٍ، عَنْ أَبِي أَيُّوبَ، عَنْ بُرَيْدٍ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، قَالَ: «الْأَعْرَافُ: كُثْبَانٌ بَيْنَ الْجَنَّةِ وَ النَّارِ، وَ الرِّجَالُ: الْأَئِمَّةُ (صَلَوَاتُ اللَّهِ عَلَيْهِمْ)، يَقِفُونَ عَلَى الْأَعْرَافِ مَعَ شِيعَتِهِمْ، وَ قَدْ سِيقَ الْمُؤْمِنُونَ إِلَى الْجَنَّةِ بِلاَ حِسَابٍ، فَيَقُولُ الْأَئِمَّةُ لِشِيعَتِهِمْ مِنْ أَصْحَابِ الذُّنُوبِ: اُنْظُرُوا إِلَى إِخْوَانِكُمْ فِي الْجَنَّةِ قَدْ سِيقُوا إِلَيْهَا بِلاَ حِسَابٍ، وَ هُوَ قَوْلُهُ تَبَارَكَ وَ تَعَالَى: ﴿سَلاٰمٌ عَلَيْكُمْ لَمْ يَدْخُلُوهٰا وَ هُمْ يَطْمَعُونَ﴾،

*7/46-49/8 អាុលី ប៊ិន អ៊ីបរ៉ហ្វីមមានប្រសាសន៍ថាឪពុកខ្ញុំបាននិយាយប្រាប់ខ្ញុំតមកពី អាល់-ហ្វាសាន់ ប៊ិន ម៉ាស៊ុប៊ុប តមកពី អៃយ៉ូប តមកពី ប៊ូរ៉យ៉ដ្ឋ តមកពី អាប៊ូ អាុប់ឌុលឡោះហ្ទ៍ صلوات الله عليه والسلام ដែលមានវចនៈថា៖ "ទីខ្ពស់ (អាល់-អាក់រ៉ហ្វ) គឺទួលនៅចន្លោះឋានសួគ៌និងឋាននរក ។ រីឯមនុស្សមួយចំនួនគឺ[ព្រះសន្ត] អ៊ីម៉ាំ عليهم السلام ដែលឈប់នៅលើទួលនោះជាមួយបណ្ដាស្ហ៊ីអាស៊ុរបស់ព្រះអង្គ عليهم السلام ។ គេនឹងជូនបណ្ដាអ្នកមានសទ្ធាទៅកាន់ឋានសួគ៌ដោយមិនទូទាត់ ។ [ព្រះសន្ត]អ៊ីម៉ាំ عليهم السلام នឹងប្រាប់បណ្ដាស្ហ៊ីអាស៊ុរបស់ព្រះអង្គ عليهم السلام ដែលបានសាងបាបថា៖ "ចូរមើលទៅបងប្អូនអស់លោកដែលនៅក្នុងឋានសួគ៌ ! គេបានជូនពួកគេទៅក្នុងឋានសួគ៌នោះ[ស្រេច]ហើយដោយមិនទូទាត់ ។ នេះគឺព្រះរាជតម្រាស់របស់អល់ឡោះហ្ទ៍ عزّ وجلّ គឺ៖ *[៧:៤៦] "សូមឲ្យពួកលោកប្រកបដោយសិរីសួស្ដី !" ពួកគេពុំទាន់បានចូលឋានសួគ៌នោះនៅឡើយទេ តែពួកគេប៉ងចង់បាន ។*

ثُمَّ يُقَالُ لَهُمْ: اُنْظُرُوا إِلَى أَعْدَائِكُمْ فِي النَّارِ، وَ هُوَ قَوْلُهُ: ﴿وَ إِذٰا صُرِفَتْ أَبْصٰارُهُمْ تِلْقٰاءَ أَصْحٰابِ النّٰارِ قٰالُوا رَبَّنٰا لاٰ تَجْعَلْنٰا مَعَ الْقَوْمِ الظّٰالِمِينَ * وَ نٰادىٰ أَصْحٰابُ الْأَعْرٰافِ رِجٰالاً يَعْرِفُونَهُمْ بِسِيمٰاهُمْ فِي النّٰارِ قٰالُوا مٰا أَغْنىٰ عَنْكُمْ جَمْعُكُمْ﴾ فِي الدُّنْيَا ﴿وَ مٰا كُنْتُمْ تَسْتَكْبِرُونَ﴾.

បន្ទាប់មក[ព្រះសន្ត]អ៊ីម៉ាំ عليهم السلام នឹងប្រាប់ពួកគេថា៖ "ចូរអស់លោកមើលទៅពួកសត្រូវរបស់អស់លោកនៅក្នុងភ្លើងនរក !" នេះគឺព្រះរាជតម្រាស់របស់អល់ឡោះហ្ទ៍ عزّ وجلّ គឺ៖ *[៧:៤៧] ពេលពួកគេក្រឡេកមើលទៅជនភ្លើងនរក ពួកគេនឹងថា៖ "ម្ចាស់អស់ទូលព្រះបង្គំជាខ្ញុំអើយ ! សូមព្រះអង្គព្រះមេត្តាកុំឲ្យអស់ទូលព្រះ*

បង្គំជាខ្ញុំនៅជាមួយជនទុច្ចរិត ។" [៧:៤៨] ជនអាល់-អាក្ពុ៌រ៉ហ្ស៊ ស្រែកទៅមនុស្សមួយចំនួនដែលពួកគេមើលស្គាល់អាស្រ័យសញ្ញាសម្គាល់របស់ពួកគេថា៖ "មិនមានប្រយោជន៍សម្រាប់អស់លោកទេ អ្វីដែលអស់លោកបានប្រមូលទុក ក្នុងហានលោក *និងសេចក្ដីក្រអឺតក្រអោងរបស់អស់លោកនោះ ។*

ثُمَّ يَقُولُونَ لِمَنْ فِي النَّارِ مِنْ أَعْدَائِهِمْ: أَ هَؤُلاَءِ شِيعَتِي وَ إِخْوَانِيَ الَّذِينَ كُنْتُمْ أَنْتُمْ تَحْلِفُونَ فِي الدُّنْيَا أَنْ لاَ يَنَالَهُمُ اللَّهُ بِرَحْمَةٍ؟ ثُمَّ تَقُولُ الْأَئِمَّةُ لِشِيعَتِهِمْ: ﴿ادْخُلُوا الْجَنَّةَ لاَ خَوْفٌ عَلَيْكُمْ وَ لاَ أَنْتُمْ تَحْزَنُونَ﴾

បន្ទាប់មក[ព្រះសន្ត]អ៊ីម៉ាំ(عليه السلام)នឹងប្រាប់ពួកសត្រូវព្រះអង្គ(عليه السلام)ដែលក្នុងភ្លើងនរកថា៖ "ស្ដ្រីអ្ចាស់ទាំងនេះ របស់ខ្ញុំ(صلوات الله عليه والسلام) បងប្អូនទាំងនេះរបស់ខ្ញុំ(صلوات الله عليه والسلام) មែនទេដែលអស់លោកបានស្បថនៅឯហានលោក *[៧:៤៩] ថាអល់ឡោះហ្ស៊ាមិនមានព្រះមេត្ដាធម៌ដល់ពួកគេទេ ?"* បន្ទាប់មក[ព្រះសន្ត]អ៊ីម៉ាំ(عليه السلام)នឹងប្រាប់បណ្ដាស្ដ្រីអ្ចាស់ៗ(عليهن السلام)ថា៖ *"[៧:៤៩] "ចូរអស់លោកអញ្ជើញចូលហានសួគ៌ចុះ អស់លោកនឹងមិនជួបទុក្ខភ័យនិងសេចក្ដីសោកសៅទេ ។"*

ثُمَّ نادىٰ أَصْحابُ النّارِ أَصْحابَ الْجَنَّةِ أَنْ أَفِيضُوا عَلَيْنا مِنَ الْماءِ أَوْ مِمّا رَزَقَكُمُ اللهُ﴾». (البرهان في تفسير القرآن ١ – الجزء : ٢ صفحة : ٥٥٢ الحديث : ٩٩/ ٣٩١١ ، مختصر بصائر الدرجات – الجزء : ١ صفحة : ٢٣١)**

បន្ទាប់ពីនោះ *[៧:៥០] ជនភ្លើងនរកនឹងស្រែកហៅជនហានសួគ៌ថា៖ "សូមលោកចាក់ទឹកមកលើយើងខ្ញុះផង ឬអ្វីដែលអល់ឡោះហ្ស៊ាបានប្រទានឲ្យអស់លោក !"* (مختصر بصائر: 231)

***

*٧/٤٦-٤٩/٩ مُحَمَّدُ بْنُ يَحْيَى عَنْ أَحْمَدَ بْنِ مُحَمَّدٍ عَنِ ابْنِ فَضَّالٍ عَنِ ابْنِ بُكَيْرٍ وَ عَلِيُّ بْنُ إِبْرَاهِيمَ عَنْ مُحَمَّدِ بْنِ عِيسَى عَنْ يُونُسَ عَنْ رَجُلٍ جَمِيعاً عَنْ زُرَارَةَ قَالَ: قَالَ لِي أَبُو جَعْفَرٍ (عَلَيْهِ السَّلاَمُ) مَا تَقُولُ فِي أَصْحَابِ الْأَعْرَافِ فَقُلْتُ مَا هُمْ إِلَّا مُؤْمِنُونَ أَوْ كَافِرُونَ إِنْ دَخَلُوا الْجَنَّةَ فَهُمْ مُؤْمِنُونَ وَ إِنْ دَخَلُوا النَّارَ فَهُمْ كَافِرُونَ

*7/46-49/9 [...] រាយការណ៍តមកពី ស៊ូរ៉ារ៉ោះតុ៌ ដែលបានថា អាប៊ូ យ៉ាកុ៊ហ្ជារ(صلوات الله عليه والسلام) បានប្រាប់ខ្ញុំថា៖ "តើលោកយល់ឃើញដូចម្ដេចអំពី *[៧:៤៨] ជនអាល់-អាក្ពុ៌រ៉ហ្ស៊ ?"* ខ្ញុំបានទូលថា៖ "ពួកគេពុំមែនអ្នកណាក្រៅពីបណ្ដាអ្នកមានសទ្ធា ឬ បណ្ដាអ្នកបដិសេធសទ្ធា ។ បើពួកគេចូលហានសួគ៌ បួកគេជាបណ្ដាអ្នកមានសទ្ធា ។ បើពួកគេចូលភ្លើងនរក ពួកគេជាបណ្ដាអ្នកបដិសេធសទ្ធា ។"

فَقَالَ وَ اللَّهِ مَا هُمْ بِمُؤْمِنِينَ وَ لَا كَافِرِينَ وَ لَوْ كَانُوا مُؤْمِنِينَ دَخَلُوا الْجَنَّةَ كَمَا دَخَلَهَا الْمُؤْمِنُونَ وَ لَوْ كَانُوا كَافِرِينَ لَدَخَلُوا النَّارَ كَمَا دَخَلَهَا الْكَافِرُونَ وَ لَكِنَّهُمْ قَوْمٌ اسْتَوَتْ حَسَنَاتُهُمْ وَ سَيِّئَاتُهُمْ فَقَصُرَتْ بِهِمُ الْأَعْمَالُ وَ إِنَّهُمْ لَكَمَا قَالَ اللَّهُ عَزَّ وَ جَلَّ

ព្រះអង្គ(صلوات الله عليه والسلام)មានវចនៈថា៖ "សូមស្បថនឹងអល់ឡោះហ្ស៊ា(عز وجل) ! ពួកគេមិនមែនអ្នកមានសទ្ធាទេ មិនមែនអ្នកបដិសេធសទ្ធាទេ ។ បើពួកគេជាអ្នកមានសទ្ធា ពួកគេនឹងបានចូលហានសួគ៌ហើយ ។ បើពួកគេជាអ្នកបដិសេធសទ្ធា ពួកគេនឹងបានចូលភ្លើងនរកហើយ ដូចពួកបដិសេធសទ្ធាចូលភ្លើងនរកនោះដែរ ។ តែពួកគេជាពួកដែលមានទង្វើល្អនិងទង្វើអាក្រក់ស្មើគ្នា ។ ដូច្នេះពួកគេខ្វះទង្វើ ដូចអល់ឡោះហ្ស៊ា(عز وجل)មានព្រះរាជបន្ទូលនោះឯង ។"

فَقُلْتُ أَ مِنْ أَهْلِ الْجَنَّةِ هُمْ أَوْ مِنْ أَهْلِ النَّارِ فَقَالَ اتْرُكْهُمْ حَيْثُ تَرَكَهُمُ اللَّهُ قُلْتُ أَ فَتُرْجِئُهُمْ قَالَ نَعَمْ أُرْجِئُهُمْ كَمَا أَرْجَأَهُمُ اللَّهُ إِنْ شَاءَ أَدْخَلَهُمُ الْجَنَّةَ بِرَحْمَتِهِ وَ إِنْ شَاءَ سَاقَهُمْ إِلَى النَّارِ بِذُنُوبِهِمْ وَ لَمْ يَظْلِمْهُمْ

ខ្ញុំបានទូលថា៖ "តើពួកគេជាអ្នកហានសួគ៌ ឬជាអ្នកហាននរក ?" ព្រះអង្គ(صلوات الله عليه والسلام)មានវចនៈថា៖ "ចូរទុកពួក

គេនៅកន្លែងដែលអល់ឡោះហ្ស៊ីវ៉ាជ ទុកពួកគេនោះទៅ ។ ខ្ញុំបានទូលថា៖ "ទូលបង្គំគប្បីទុកពួកគេនៅពេលក្រោយ ?" ព្រះអង្គ ﷺ មានវចនៈថា៖ "ត្រូវហើយ ! ទុកពួកគេនៅពេលក្រោយទៅ ។ បើអល់ឡោះហ្ស៊ីវ៉ាជ ចង់ ព្រះអង្គ ﷻ នឹងឲ្យពួកគេចូលហានសូគិដោយសេក្តីអាណិតអាសូរ ។ បើព្រះអង្គ ﷻ ចង់ ព្រះអង្គ ﷻ នឹងឲ្យពួកគេចូលភ្លើងនរកដោយសារបាបពួកគេ ។ ព្រះអង្គ ﷻ មិនប្រព្រឹត្តដោយអយុត្តិធម៌ចំពោះពួកគេទេ ។"

فَقُلْتُ هَلْ يَدْخُلُ الْجَنَّةَ كَافِرٌ قَالَ لَا قُلْتُ هَلْ يَدْخُلُ النَّارَ إِلَّا كَافِرٌ قَالَ فَقَالَ لَا إِلَّا أَنْ يَشَاءَ اللَّهُ يَا زُرَارَةُ إِنِّي أَقُولُ مَا شَاءَ اللَّهُ وَ أَنْتَ لَا تَقُولُ مَا شَاءَ اللَّهُ أَمَا إِنَّكَ إِنْ كَبِرْتَ رَجَعْتَ وَ تَحَلَّلَتْ عَنْكَ عُقَدُكَ. (الكافي – الجزء : ٢ صفحة : ٤٠٨ الحديث : ١)

ខ្ញុំបានទូលថា៖ "តើអ្នកបដិសេធសទ្ធាចូលហានសូគិទេ ?" ព្រះអង្គ ﷺ មានវចនៈថា៖ "ទេ ។" ខ្ញុំបានទូលថា៖ "តើគេអាចចូលភ្លើងនរកទេ ក្រៅពីអ្នកបដិសេធសទ្ធា ?" ព្រះអង្គ ﷺ មានវចនៈថា៖ "ទេ ។ លើកលែងតែអល់ឡោះហ្ស៊ីវ៉ាជ ចង់ ។ ស្វ៊ារ៉ោះតុ៌អើយ ! ខ្ញុំ ﷺ ថា៖ "ស្រេចតែអល់ឡោះហ្ស៊ីវ៉ាជ ចង់" ។ លោកមិនថា "ស្រេចតែអល់ឡោះហ្ស៊ីវ៉ាជ ចង់" ទេ ។ តែពេលលោកចាស់ លោកនឹងបកក្រោយ ចំណងលោកនឹងធ្ងរ (លើអ្នកប្រឆាំងលោក) ។" (الكافي 2: 408/ 1)

***

*٧/٤٦-٤٩/١٠ عَنْ كَرَّامٍ، قَالَ: سَمِعْتُ أَبَا عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ) يَقُولُ: «إِذَا كَانَ يَوْمُ الْقِيَامَةِ أَقْبَلَ سَبْعُ قِبَابٍ مِنْ نُورٍ يَوَاقِيتَ خُضْرٍ وَ بِيضٍ، فِي كُلِّ قُبَّةٍ إِمَامُ دَهْرِهِ، قَدِ احْتَفَّ بِهِ أَهْلُ دَهْرِهِ، بَرُّهَا وَ فَاجِرُهَا، حَتَّى يَقِفُوا بِبَابِ الْجَنَّةِ،

*7/46-49/10 រាយការណ៍មកពី ការ៉ាំ ដែលមានប្រសាសន៍ថាខ្ញុំបានឮ អាប៊ូ អ្ពាប់ឌុលឡោះ ﷺ មានវចនៈថា៖ "ដល់ថ្ងៃជំនុំជម្រះ នឹងមានដោមរស្មីប្រាំពីរ មានពណ៌ត្បូងក្រហមស ។ នៅក្នុងដោមនីមួយៗមាន[ព្រះសន្ត]អ៊ីម៉ាំសម័យកាលមួយអង្គ ﷺ ។ ប្រជានិករនៃសម័យកាលព្រះអង្គ ﷺ នឹងតាមជាប់ក្នុងសម័យកាលនោះ មានបុគ្គលត្រឹមត្រឹម មានបុគ្គលអសីលធម៌ លុះទៅដល់មាត់ទ្វារហានសូគិ ។

فَيَطَّلِعُ أَوَّلُهَا صَاحِبَ قُبَّةٍ اطِّلاَعَةً فَيُمَيِّزُ أَهْلَ وَلاَيَتِهِ مِنْ عَدُوِّهِ، ثُمَّ يُقْبِلُ عَلَى عَدُوِّهِ فَيَقُولُ: أَنْتُمُ الَّذِينَ أَقْسَمْتُمْ لاَ يَنَالُهُمُ اللَّهُ بِرَحْمَةٍ؟! أُدْخُلُوا الْجَنَّةَ لاَ خَوْفٌ عَلَيْكُمُ الْيَوْمَ، يَقُولُهُ لِأَصْحَابِهِ،

ម្ចាស់ ﷺ ដោមរស្មីទីមួយនឹងពិនិត្យមើល ហើយវែកញែកបណ្តាស្ត្រីអាស៊ុំព្រះអង្គ ﷺ ចេញពីបណ្តាសត្រូវព្រះអង្គ ﷺ ។ បន្ទាប់មកព្រះអង្គ ﷺ នឹងប្រឈមមុខនឹងបណ្តាសត្រូវព្រះអង្គ ﷺ ហើយមានវចនៈថា៖ "ពួកអ្នកមែនទេដែល *[៧:៤៩] ធ្លាប់ស្បថថាអល់ឡោះហ្ស៊ាមិនមានព្រះមេត្តាធម៌ដល់ពួកគេទេ ?"* [ហើយព្រះអង្គ ﷺ បែរទៅរកស្ត្រីអ្ពាស៊ុំព្រះអង្គ ﷺ ថា៖] *"[៧:៤៩] ចូរអស់លោកអញ្ជើញចូលហានសូគិចុះ អស់លោកនឹងមិនជួបទុក្ខភ័យទេ* ថ្ងៃនេះ ។"

فَيَسْوَدُّ وَجْهُ الظَّالِمِ، فَيَمُرُّ أَصْحَابُهُ إِلَى الْجَنَّةِ، وَ هُمْ يَقُولُونَ: ﴿رَبَّنَا لاَ تَجْعَلْنَا مَعَ الْقَوْمِ الظَّالِمِينَ﴾ فَإِذَا نَظَرَ أَهْلُ الْقُبَّةِ الثَّانِيَةِ إِلَى قِلَّةِ مَنْ يَدْخُلُ الْجَنَّةَ، وَ كَثْرَةِ مَنْ يَدْخُلُ النَّارَ، خَافُوا أَنْ لاَ يَدْخُلُوهَا، وَ ذَلِكَ قَوْلُهُ: ﴿لَمْ يَدْخُلُوهَا وَ هُمْ يَطْمَعُونَ﴾». (البرهان في تفسير القرآن ١ – الجزء : ٢ صفحة : ٥٥٤ الحديث : ٩٩/ ٣٩٢١ ، تفسير العيّاشي – الجزء : ٢ صفحة : ١٨ الحديث : ٤٧)**

មុខពួកទុច្ចរិតនឹងខ្មៅ បណ្តាសាវកព្រះអង្គ ﷺ នឹងឆ្លងទៅកាន់ហានសូគិ ។ ពួកគេនឹងថា៖ *[៧:៤៧] ម្ចាស់អស់ទូលព្រះបង្គំជាខ្ញុំអើយ ! សូមព្រះអង្គព្រះមេត្តាកុំឲ្យអស់ទូលព្រះបង្គំជាខ្ញុំនៅជាមួយជនទុច្ចរិត"* ពេលជនដោមទីពីរឃើញថាកម្រមានអ្នកចូលហានសូគិ សម្ប៉ូរអ្នកចូលភ្លើងនរក ព្រោះតែខ្លាចចូលក្នុងភ្លើងនរកនោះដែរ ។ នេះគឺព្រះរាជតម្រាសរបស់អល់ឡោះហ្ស៊ីវ៉ាជ *[៧:៤៦] ពួកគេពុំទាន់បានចូលហាន*

សួគ៌នោះនៅឡើយទេ តែពួកគេប៉ងចង់បាន ។" (تفسير العيّاشي 2: 18/ 47)

***

*٤٦/٧-٤٩/١١ [القطب الراوندي] رَوَى أَبُو حَمْزَةَ اَلثُّمَالِيُّ، عَنْ أَبِي جَعْفَرٍ (عَلَيْهِ السَّلاَمُ) قَالَ: قَالَ ابن الكواء [لعلي (عليه السلام)]: يَا أَمِيرَ اَلْمُؤْمِنِينَ * (وَ عَلَى اَلْأَعْرَافِ رِجَالٌ يَعْرِفُونَ كُلاًّ بِسِيمَاهُمْ) *. قَالَ: نَحْنُ اَلْأَعْرَافُ نَعْرِفُ أَنْصَارَنَا بِسِيمَاهُمْ، وَ نَحْنُ أَصْحَابُ اَلْأَعْرَافِ نُوقَفُ بَيْنَ اَلْجَنَّةِ وَ اَلنَّارِ، فلا يَدْخُلُ اَلْجَنَّةَ إِلاَّ مَنْ عَرَفَنَا وَ عَرَفْنَاهُ، وَ لاَ يَدْخُلُ اَلنَّارَ إِلاَّ مَنْ أَنْكَرَنَا وَ أَنْكَرْنَاهُ.

*7/46-49/11 [...] រាយការណ៍តមកពី អាប៊ូ យ៉ាក្កុហ្វារ صلوات الله عليه والسلام ដែលមានវចនៈថា៖ "អ៊ីបនូ អាល់-កាវ៉ាអ៊ុ បានទូលអាលី صلوات الله عليه والسلام ថា៖ "អាមីរុល-មុមីនីន صلوات الله عليه والسلام អឺយ ! *[៧:៤៦] នៅលើអាល់-អាក់រ៉ហ្វ៍មានមនុស្សមួយចំនួនដែលមើលស្គាល់គ្នាអាស្រ័យសញ្ញាសម្គាល់របស់ពួកគេ ។"* ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "យើង عليهم السلام ជាអ្នកស្គាល់ ។ យើង عليهم السلام ស្គាល់អ្នកជួយយើង عليهم السلام អាស្រ័យសញ្ញាសម្គាល់ពួកគេ ។ យើង عليهم السلام ជាម្ចាស់អាល់-អាក់រ៉ហ្វ៍ (ទីខ្ពស់) ។ យើង عليهم السلام នឹងឈប់នៅចន្លោះឋានសួគ៌និងភ្លើងនរក (ឋាននរក) ។ ដូច្នេះ ពុំមានអ្នកណាមួយចូលឋានសួគ៌ទេក្រៅពីបុគ្គលដែលស្គាល់យើង عليهم السلام ដែលយើង عليهم السلام ស្គាល់បុគ្គលនោះ ។ ពុំមានអ្នកណាមួយចូលឋាននរកទេក្រៅពីបុគ្គលដែលបដិសេធយើង عليهم السلام ដែលយើង عليهم السلام បដិសេធបុគ្គលនោះ ។

وَ كَانَ عَلِيٌّ (عَلَيْهِ السَّلاَمُ) يُخَاطِبُهُ بِوَيْحِكَ، وَ كَانَ يَتَشَيَّعُ، فَلَمَّا كَانَ يَوْمُ اَلنَّهْرَوَانِ قَاتَلَ عَلِيّاً (عَلَيْهِ السَّلاَمُ) اِبْنُ اَلْكَوَّاءِ. (تفسير أبي حمزة الثمالي - الجزء : ١ صفحة : ١٩ الحديث : ١٠٠)

[លោកអ្នកអធិប្បាយថា៖] អាលី صلوات الله عليه والسلام បានហៅគាត់ (អ៊ីបនូ អាល់-កាវ៉ាអ៊ុ) ថា "អបមង្គលលើអ្នកឯង" កាលគាត់នឹងទៅជាស្ហ៊ីអាស់ ។ នៅក្នុងសមរភូមិ អាល់-ណាស្ហ៍រ៉វ៉ាន់ អាលី صلوات الله عليه والسلام បានសម្លាប់ អ៊ីបនូ អាល់-កាវ៉ាអ៊ុ ។" (تفسير أبي حمزة الثمالي 1: 19/ 100)

وَنَادَىٰٓ أَصۡحَٰبُ ٱلنَّارِ أَصۡحَٰبَ ٱلۡجَنَّةِ أَنۡ أَفِيضُواْ عَلَيۡنَا مِنَ ٱلۡمَآءِ أَوۡ مِمَّا رَزَقَكُمُ ٱللَّهُۚ قَالُوٓاْ إِنَّ ٱللَّهَ حَرَّمَهُمَا عَلَى ٱلۡكَٰفِرِينَ ۝٥٠

៥០. ជនភ្លើងនរកនឹងស្រែកហៅជនឋានសួគ៌ថា៖ "សូមលោកចាក់ទឹកមកលើយើងខ្លះផង ឬអ្វីដែលអល់ឡោះហ្ទ៍បានប្រទានឲ្យអស់លោក !" ពួកគេនឹងថា៖ "អល់ឡោះហ្ទ៍បានហាម[វត្ថុ]ទាំងពីរចំពោះជនបដិសេធសទ្ធា ។"

អធិប្បាយអាយ៉ាត់ ៥០

١/٥٠/٧ اَلْعَيَّاشِيُّ: عَنْ إِبْرَاهِيمَ بْنِ عَبْدِ الْحَمِيدِ، عَنْ أَحَدِهِمَا، قَالَ: «إِنَّ أَهْلَ النَّارِ يَمُوتُونَ عَطَاشَى، وَ يَدْخُلُونَ قُبُورَهُمْ عَطَاشَى، وَ يُحْشَرُونَ عَطَاشَى، وَ يَدْخُلُونَ جَهَنَّمَ عَطَاشَى، فَتُرْفَعُ لَهُمْ قَرَابَاتُهُمْ مِنَ الْجَنَّةِ، فَيَقُولُونَ: ﴿أَفِيضُوا عَلَيْنَا مِنَ الْمَاءِ أَوْ مِمَّا رَزَقَكُمُ اللَّهُ﴾». (البرهان في تفسير القرآن ١ - الجزء : ٢ صفحة : ٥٥٧ الحديث : ٩٩/ ٣٩٢٦ ، تفسير العيّاشي - الجزء : ٢ صفحة : ١٩ الحديث : ٤٩)**

7/50/1 [...] អ៊ីម៉ាំមួយអង្គ صلوات الله عليه والسلام (អ៊ីម៉ាំទី៥ ឬ ទី៦ صلوات الله عليه والسلام) មានវចនៈថា៖ "ជនភ្លើងនរកនឹងស្រេកទឹកស្ទើរស្លាប់ ។ ពួកគេនឹងចូលក្នុងផ្នូរដោយស្រេកទឹក ។ ពួកគេនឹងត្រូវប្រជុំគ្នា (ថ្ងៃជំនុំជម្រះ) ដោយស្រេកទឹក ហើយពួកគេនឹងចូលទៅក្នុងនរកដោយស្រេកទឹក ។ ពួកគេនឹងលែងបាននៅក្បែរឋានសួគ៌ ។ ពួកគេនឹងថា៖ *[៧:៥០] "សូមលោកចាក់ទឹកមកលើយើងខ្លះផង ឬអ្វីដែលអល់ឡោះហ្ទ៍បានប្រទានឲ្យអស់*

លោក !" (تفسير العيّاشي 2: 19/ 49)

***

٢/٥٠/٧ ابْنُ بَابَوَيْهِ: عَنْ أَبِيهِ، قَالَ: حَدَّثَنَا سَعْدُ بْنُ عَبْدِ اللهِ، عَنِ الْقَاسِمِ بْنِ مُحَمَّدٍ الْأَصْبَهَانِيِّ، عَنْ سُلَيْمَانَ ابْنِ دَاوُدَ، عَنْ حَفْصِ بْنِ غِيَاثٍ، عَنْ أَبِي عَبْدِ اللهِ (عَلَيْهِ السَّلَامُ)، قَالَ: «يَوْمَ التَّلَاقِ: يَوْمَ يَلْتَقِي أَهْلُ السَّمَاءِ وَ أَهْلُ الْأَرْضِ، وَ يَوْمَ التَّنَادِ: يَوْمَ يُنَادِي أَهْلُ النَّارِ أَهْلَ الْجَنَّةِ ﴿أَنْ أَفِيضُوا عَلَيْنا مِنَ الْماءِ أَوْ مِمَّا رَزَقَكُمُ اللهُ﴾، وَ يَوْمُ التَّغَابُنِ يَوْمٌ يَغْبِنُ أَهْلُ الْجَنَّةِ أَهْلَ النَّارِ، وَ يَوْمُ الْحَسْرَةِ: يَوْمٌ يُؤْتَى بِالْمَوْتِ فَيُذْبَحُ». (البرهان في تفسير القرآن ١ – الجزء : ٣ صفحة : ٧١٣ الحديث : ٩٩/ ٦٨٨٦ ، معاني الأخبار – الجزء : ١ صفحة : ١٥٦ الحديث : ١)**

7/50/2 អ៊ីបនូ បាប៊ូវ៉ៃហ៍ [...] ហ្វាហ្ស៍ ប៊ីន ក៏យ៉ាស្ហ៍ បានតំណាលតមកពី អាប៊ូ អាប់ឌុលឡោះហ៍ صلوات الله عليه والسلام ដែលមានវចនៈថា៖ "ថ្ងៃជួបជុំ (يَوْمَ التَّلَاقِ) គឺថ្ងៃដែលប្រជានិករមេឃនិងជួបប្រជានិករដី ។ ថ្ងៃស្រែកហៅ (يَوْمَ التَّنَادِ) គឺថ្ងៃដែលជនឋាននរកនឹងស្រែកហៅជនឋានសួគ៌ *[៧:៥០] "សូមលោកចាក់ទឹកមកលើយើងខ្លះផង ឬអ្វីដែលអល់ឡោះហ៍បានប្រទានឲ្យអស់លោក !"* ថ្ងៃវិនាសនិងចំណេញ (يَوْمُ التَّغَابُنِ) គឺថ្ងៃដែលជនឋានសួគ៌នឹងបានផលចំណេញលើសជនភ្លើងនរក ។ ថ្ងៃសោកស្ដាយ (يَوْمُ الْحَسْرَةِ) គឺថ្ងៃដែលគេនឹងនាំខ្លួនការស្លាប់មក ហើយគេនឹងសំឡេះ (គឺសម្លាប់) ការស្លាប់នោះ (ការស្លាប់នោះមានរូបរាងដូចសត្វលោកដែរ) ។" (معاني الأخبار: 1/ 156) 19:39

ٱلَّذِينَ ٱتَّخَذُواْ دِينَهُمۡ لَهۡوٗا وَلَعِبٗا وَغَرَّتۡهُمُ ٱلۡحَيَوٰةُ ٱلدُّنۡيَاۚ فَٱلۡيَوۡمَ نَنسَىٰهُمۡ كَمَا نَسُواْ لِقَآءَ يَوۡمِهِمۡ هَٰذَا وَمَا كَانُواْ بِـَٔايَٰتِنَا يَجۡحَدُونَ ﴿٥١﴾

៥១. ពួកដែលបានយកសាសនារបស់ខ្លួនជាការកំសាន្តនិងជាល្បែង ជីវិតលោកនេះបោកបញ្ឆោតពួកគេ ។ ដូច្នេះថ្ងៃនេះយើងនឹងភ្លេចពួកគេ ដូចពួកគេបានភ្លេច (គឺបដិសេធ មិនទទួលស្គាល់) ថានឹងបានជួបថ្ងៃនេះដែរ ព្រោះតែពួកគេបានបដិសេធបណ្ដាព្រះសញ្ញាយើង ។

وَلَقَدۡ جِئۡنَٰهُم بِكِتَٰبٖ فَصَّلۡنَٰهُ عَلَىٰ عِلۡمٍ هُدٗى وَرَحۡمَةٗ لِّقَوۡمٖ يُؤۡمِنُونَ ﴿٥٢﴾

៥២. យើងបាននាំព្រះគម្ពីរមួយមកឲ្យពួកគេ ដែលយើងបានអធិប្បាយបំភ្លឺដោយអភិញ្ញា ជាមគ្គទេសក៍ដឹកនាំនិងជាព្រះមេត្តាធម៌សម្រាប់ជនានុជនដែលមានសទ្ធា ។

هَلۡ يَنظُرُونَ إِلَّا تَأۡوِيلَهُۥۚ يَوۡمَ يَأۡتِي تَأۡوِيلُهُۥ يَقُولُ ٱلَّذِينَ نَسُوهُ مِن قَبۡلُ قَدۡ جَآءَتۡ رُسُلُ رَبِّنَا بِٱلۡحَقِّ فَهَل لَّنَا مِن شُفَعَآءَ فَيَشۡفَعُواْ لَنَآ أَوۡ نُرَدُّ فَنَعۡمَلَ غَيۡرَ ٱلَّذِي كُنَّا نَعۡمَلُۚ قَدۡ خَسِرُوٓاْ أَنفُسَهُمۡ وَضَلَّ عَنۡهُم مَّا كَانُواْ يَفۡتَرُونَ ﴿٥٣﴾

៥៣. តើពួកគេរង់ចាំអ្វី ក្រៅពីរង់ចាំឲ្យវា (គឺការព្រមានរបស់គម្ពីរ) បានសម្រេច ? ថ្ងៃដែលវានឹងបានសម្រេចជនដែលបានភ្លេចវាពីមុននឹងថា៖ "បណ្ដាព្រះសាសនៈទូតរបស់ម្ចាស់យើងបាននាំមកនូវការពិត (គឺបានមកប្រាប់យើងហើយ) ។ តើមានអ្នកជួយធ្វើអន្តរាគមន៍សម្រាប់យើងទេ ដើម្បីនឹងជួយធ្វើអន្តរាគមន៍ឲ្យយើង ? ឬតើគេអាចឲ្យយើងត្រឡប់វិញទេ [មកឯផែនដី] ដើម្បីយើងនឹងធ្វើផ្សេងពីអ្វីដែលយើងធ្លាប់បានធ្វើហើយនោះ ?" ពួកគេធ្វើឲ្យខ្លួនឯងវិនាស ។ អ្វី (គឺរូបបដិមាទាំងឡាយ) ដែលពួកគេបានប្រឌិតឡើងនោះនឹងបោះបង់ពួកគេចោល ។

***

អ៊ីម៉ាំ អាប៊ូ យ៉ាក់ហ្វារ ស្វ៉ឌិក្ខ صلوات الله عليه والسلامបានថ្លែងអំពីអាយ៉ាស់អល់ឡោះហ៍ عز وجلនេះថា៖ "តាក់វីល (អត្ថន័យកំបាំង) របស់អាយ៉ាស់នេះខុសពីស្ហ៊ហ្វៀរ៍ (អត្ថន័យច្បាស់លាស់) ។ អាយ៉ាស់នេះសំដៅទៅលើការងើបឡើងវិញរបស់អ៊ីម៉ាំ អាល់-ស្វាម៉ាន عجل الله فرجكនិងថ្ងៃជំនុំជម្រះ ។ *ជនទាំងឡាយដែលបានភ្លេចវាពីមុននោះ* សំដៅទៅលើបណ្ដាអ្នកដែលមិនយកចិត្តទុកដាក់អំពីអ៊ីម៉ាំ អាល់-ស្វាម៉ាន់ عجل الله فرجك ។ នាថ្ងៃជំនុំជម្រះ ពួកគេនឹងថា៖ *"សាស្ដាទាំងឡាយរបស់ព្រះម្ចាស់យើងបាននាំមកនូវការពិតហើយ ។ តើមានអ្នកធ្វើអន្តរាគមន៍សម្រាប់យើងទេ ដើម្បីនឹងជួយធ្វើអន្តរាគមន៍ឲ្យយើង ? ឬតើគេអាចបញ្ជូនយើងត្រឡប់វិញ ទេ ដើម្បីយើងនឹងធ្វើអំពើផ្សេងពីអំពើដែលយើងធ្លាប់បានធ្វើហើយនោះ ?"* (តាហ្វសៀរ គូម្មី ក្បាលទី ១ ទំព័រ ២៣៥)

អធិប្បាយអាយ៉ាស់ ៥១-៥៣

٧/٥١–١/٥٣ ابْنُ بَابَوَيْهِ، قَالَ: حَدَّثَنَا مُحَمَّدُ بْنُ مُحَمَّدِ بْنِ عِصَامٍ الْكُلَيْنِيُّ (رَحِمَهُ اللَّهُ)، قَالَ: حَدَّثَنَا مُحَمَّدُ بْنُ يَعْقُوبَ الْكُلَيْنِيُّ، قَالَ: حَدَّثَنَا عَلِيُّ بْنُ مُحَمَّدٍ الْمَعْرُوفُ بِعَلاَّنَ، قَالَ: حَدَّثَنَا أَبُو حَامِدٍ عِمْرَانُ بْنُ مُوسَى بْنِ إِبْرَاهِيمَ، عَنِ الْحَسَنِ بْنِ قَاسِمٍ الرَّقَّامِ، عَنِ الْقَاسِمِ بْنِ مُسْلِمٍ، عَنْ أَخِيهِ عَبْدِ الْعَزِيزِ بْنِ مُسْلِمٍ، قَالَ: سَأَلْتُ الرِّضَا (عَلَيْهِ السَّلاَمُ) عَنْ قَوْلِ اللَّهِ عَزَّ وَ جَلَّ: ﴿نَسُوا اللهَ فَنَسِيَهُمْ﴾. فَقَالَ: «إِنَّ اللَّهَ تَبَارَكَ وَ تَعَالَى لاَ يَنْسَى وَ لاَ يَسْهُو، وَ إِنَّمَا يَنْسَى وَ يَسْهُو الْمَخْلُوقُ الْمُحْدَثُ، أَ لاَ تَسْمَعُهُ عَزَّ وَ جَلَّ يَقُولُ: ﴿وَ مٰا كٰانَ رَبُّكَ نَسِيًّا﴾ وَ إِنَّمَا يُجَازِي مَنْ نَسِيَهُ وَ نَسِيَ لِقَاءَ يَوْمِهِ بِأَنْ يُنْسِيَهُمْ أَنْفُسَهُمْ، كَمَا قَالَ اللَّهُ عَزَّ وَ جَلَّ: ﴿وَ لاٰ تَكُونُوا كَالَّذِينَ نَسُوا اللّٰهَ فَأَنْسٰاهُمْ أَنْفُسَهُمْ أُولٰئِكَ هُمُ الْفٰاسِقُونَ﴾، وَ قَوْلُهُ عَزَّ وَ جَلَّ: ﴿فَالْيَوْمَ نَنْسٰاهُمْ كَمٰا نَسُوا لِقٰاءَ يَوْمِهِمْ هٰذٰا﴾، أَيْ نَتْرُكُهُمْ كَمَا تَرَكُوا الاِسْتِعْدَادَ لِلِقَاءِ يَوْمِهِمْ هَذَا». (البرهان في تفسير القرآن ١ – الجزء : ٢ صفحة : ٨١٣ الحديث : ٩٩/ ٤٦٢٢ ، التوحيد – الجزء : ١ صفحة : ١٥٩ الحديث : ١ ، عيون أخبار الرّضا (عليه السّلام) – الجزء : ١ صفحة : ١٢٥ الحديث : ١٨)**

7/51-53/1 [...] អ៊ុប់ឌុល អ៊ុស៊ីស ប៊ិន មុស្លីម បានតំណាលថាខ្ញុំបានសួរ អាល់-រីដ៏ صلوات الله عليه والسلام អ៊ុលី صلوات الله عليه والسلام ប៊ិន មូសា صلوات الله عليه والسلام អំពីព្រះបន្ទូលអល់ឡោះហ៍ عز وجل *[៩:៦៧] ពួកគេភ្លេចអល់ឡោះហ៍ ដូច្នេះព្រះអង្គភ្លេចពួកគេ ។* ព្រះអង្គ صلوات الله عليه والسلامមានវចនៈថា៖ "អល់ឡោះហ៍ تبارك وتعالىមិនភ្លេច មិនខុសឆ្គងទេ ។ សត្វលោកទេដែលភ្លេច ដែលភ្លាំងភ្លាត់ស្មារតី ។ លោកមិនបានឮអល់ឡោះហ៍ عز وجلមានព្រះបន្ទូលទេថា៖ *[១៩:៦៤] ព្រះម្ចាស់អ្នកមិនហៃភ្លេចទេ ?* តែព្រះអង្គ عز وجلតបស្នងបុគ្គលដែលភ្លេចព្រះអង្គ عز وجل ដែលភ្លេចថានឹងបានជួបព្រះអង្គ عز وجلនាថ្ងៃនោះ (គឺថ្ងៃជំនុំជម្រះ) ដោយធ្វើឲ្យបុគ្គលនោះភ្លេចខ្លួនឯង ដូចអល់ឡោះហ៍ عز وجلមានព្រះបន្ទូលថា៖ *[៥៩:១៩] ចូរពួកអ្នកកុំដូចបណ្ដាអ្នកដែលភ្លេចអល់ឡោះហ៍ ដូច្នេះព្រះអង្គធ្វើឲ្យពួកគេភ្លេចខ្លួនឯង ។ ជនទាំងនោះជាជនល្មើស* និងព្រះបន្ទូលអល់ឡោះហ៍ عز وجل *[៧:៥១] ដូច្នេះថ្ងៃនេះយើងនឹងភ្លេចពួកគេ ដូចពួកគេបានភ្លេចថានឹងបានជួបថ្ងៃនេះដែរ* ពោលគឺព្រោះតែពួកគេមិនអើពើនឹងការប្រុងប្រៀបខ្លួនដើម្បីជួបថ្ងៃនេះ ។" (التوحيد 1: 159 /1, عيون أخبار الرّضا (عليه السّلام) 1: 125 /18) 19:64-65; 59:18-19; 9:64-67

***

*٧/٥١–٢/٥٣ فِي كِتَابِ اَلتَّوْحِيدِ عَنْ أَمِيرِ اَلْمُؤْمِنِينَ عَلَيْهِ اَلسَّلاَمُ حَدِيثٌ طَوِيلٌ يَقُولُ فِيهِ عَلَيْهِ اَلسَّلاَمُ: وَ قَدْ سَأَلَهُ رَجُلٌ، عَمَّا اِشْتَبَهَ عَلَيْهِ مِنْ آيَاتِ اَلْكِتَابِ: وَ كَذَلِكَ تَفْسِيرُ قَوْلِهِ عَزَّ وَ جَلَّ: «فَالْيَوْمَ نَنْسٰاهُمْ كَمٰا نَسُوا لِقٰاءَ يَوْمِهِمْ هٰذٰا» يَعْنِي بِالنِّسْيَانِ أَنَّهُ لَمْ يُثِبْهُمْ كَمَا يُثِيبُ أَوْلِيَاءَهُ اَلَّذِينَ كَانُوا فِي دَارِ اَلدُّنْيَا مُطِيعِينَ ذَاكِرِينَ حِينَ آمَنُوا بِهِ وَ بِرُسُلِهِ وَ خَافُوهُ بِالْغَيْبِ وَ قَدْ يَقُولُ اَلْعَرَبُ فِي بَابِ اَلنِّسْيَانِ: قَدْ نَسِيَنَا فُلاَنٌ فَلاَ يَذْكُرُنَا، أَيِ إِنَّهُ لاَ يَأْمُرُ لَهُمْ بِخَيْرٍ وَ لاَ يَذْكُرُهُمْ بِهِ. (تفسير نور الثقلين ج٢ ص٣٧)

*7/51-53/2 នៅក្នុងសាត្រាតៅហ៊ីដ្ឋ រាយការណ៍មកពី អាមីរុល-មុមីនីន صلوات الله عليه والسلام នៅក្នុងហាឌីស្សវែងមួយ ។ ព្រះអង្គ صلوات الله عليه والسلامមានវចនៈនៅក្នុងហាឌីស្សនោះ កាលបុរសម្នាក់បានសួរព្រះអង្គ صلوات الله عليه والسلامអំពីចម្ងល់

អាយ៉ាស៊ុ០ព្រះគម្ពីរ ថា៖ "ស្រដៀងនឹងនោះដែរគឺការបកស្រាយព្រះរាជបន្ទូលអល់ឡោះហ្ស៊ីដ ﷻ *[៧:៥១] ដូច្នេះថ្ងៃនេះយើងនឹងភ្លេចពួកគេ ដូចពួកគេបានភ្លេចថានឹងបានជួបថ្ងៃនេះដែរ ។* ភ្លេចមានន័យអល់ឡោះហ្ស៊ីដ ﷻនឹងមិនឲ្យរង្វាន់ជនទុច្ចរិតដូចព្រះអង្គ ﷻនឹងឲ្យរង្វាន់បណ្តាមិត្តព្រះអង្គ ﷻនោះទេ ដែលបានស្តាប់បង្គាប់ព្រះអង្គ ﷻនៅក្នុងឋានលោក ដែលបានរំលឹក ដែលបានជឿព្រះអង្គ ﷻនិងព្រះសាសនៈទូតទាំងឡាយ عليهم السلام របស់ព្រះអង្គ ﷻ ដែលខ្លាចព្រះអង្គ ﷻក្នុងអាថិកំបាំង ។ ពួកអារ៉ាប់ធ្លាប់តែថា "អ្នកនេះភ្លេចយើង មិនរំលឹកយើងទេ" ពោលគឺអ្នកនោះមិនណែនាំពួកគេឲ្យធ្វើល្អទេ មិនរំនឹកពួកគេរឿងធ្វើល្អទេ ។" (تفسير نور الثقلين 2: 37)

إِنَّ رَبَّكُمُ ٱللَّهُ ٱلَّذِى خَلَقَ ٱلسَّمَٰوَٰتِ وَٱلْأَرْضَ فِى سِتَّةِ أَيَّامٍ ثُمَّ ٱسْتَوَىٰ عَلَى ٱلْعَرْشِ ۖ يُغْشِى ٱلَّيْلَ ٱلنَّهَارَ يَطْلُبُهُۥ حَثِيثًا وَٱلشَّمْسَ وَٱلْقَمَرَ وَٱلنُّجُومَ مُسَخَّرَٰتٍۭ بِأَمْرِهِۦٓ ۗ أَلَا لَهُ ٱلْخَلْقُ وَٱلْأَمْرُ ۗ تَبَارَكَ ٱللَّهُ رَبُّ ٱلْعَٰلَمِينَ ﴿٥٤﴾

៥៤. ម្ចាស់ពួកអ្នកគឺអល់ឡោះហ្ស៊ី ព្រះអង្គបានបង្កើតមេឃទាំងឡាយនិងដីក្នុងរយៈពេលប្រាំមួយថ្ងៃ បន្ទាប់មកព្រះអង្គបានសម្តែងព្រះរាជឆន្ទៈព្រះអង្គលើព្រះរាជបល្ល័ង្ក ។ ព្រះអង្គគ្របដណ្តប់ពេលថ្ងៃដោយពេលរាត្រីដែលប្រដេញតាមវាយ៉ាងស្ងិតស្ងាញ ។ [អល់ឡោះហ្ស៊ីបានបង្កើត]ដួងអាទិត្យ ដួងចន្ទ និងដួងតារាទាំងឡាយ ដែលគោរពតាមព្រះរាជបញ្ជាព្រះអង្គ ។ មិនអាចប្រកែកបានទេ ការបង្កើតនិងព្រះរាជបញ្ជាជាកម្មសិទ្ធិរបស់ព្រះអង្គ ។ សូមពរជ័យសិរីសួស្តីមានដល់អល់ឡោះហ្ស៊ី ម្ចាស់ពិភពទាំងពួង ។

អធិប្បាយអាយ៉ាស៊ុ ៥៤

٧/٥٤/١ صَاحِبُ (ثَاقِبِ الْمَنَاقِبِ): أَسْنَدَهُ إِلَى أَبِي هَاشِمٍ الْجَعْفَرِيِّ، عَنْ مُحَمَّدِ بْنِ صَالِحٍ الْأَرْمَنِيِّ، قَالَ: قُلْتُ لِأَبِي مُحَمَّدٍ الْحَسَنِ الْعَسْكَرِيِّ (عَلَيْهِ السَّلاَمُ): عَرِّفْنِي عَنْ قَوْلِ اللهِ تَعَالَى: ﴿لِلّٰهِ الْأَمْرُ مِنْ قَبْلُ وَ مِنْ بَعْدُ﴾. قَالَ (عَلَيْهِ السَّلاَمُ): «لِلّٰهِ الْأَمْرُ مِنْ قَبْلِ أَنْ يَأْمُرَ، وَ مِنْ بَعْدِ أَنْ يَأْمُرَ بِمَا يَشَاءُ».

7/54/1 [...] មូហ្ចាំម៉ាដ្ឋ ប៊ិន ស្ម៊ីលិះហ្ស៊ អាល់-អារ៉ានី បានថាខ្ញុំបានសួរ អាប៊ូ មូហ្ចាំម៉ាដ្ឋ អាល់-ហ្ចាសាន់ អាល់-អ្ចាស់ការី صلوات الله عليه والسلام ថា៖ "សូមព្រះអង្គ صلوات الله عليه والسلام ពន្យល់ទូលបង្គំព្រះបន្ទូលអល់ឡោះហ្ស៊ីដ ﷻ *[៣០:៤] ព្រះរាជបញ្ជាជាកម្មសិទ្ធិរបស់អល់ឡោះហ្ស៊ី គ្រាមុននិងគ្រាក្រោយ ។* ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "ព្រះបញ្ជាជារបស់អល់ឡោះហ្ស៊ី ﷻមុនព្រះអង្គ ﷻបញ្ជានិងក្រោយព្រះអង្គ ﷻបញ្ជា ស្រេចតែព្រះអង្គ ﷻចង់ ។

فَقُلْتُ فِي نَفْسِي: هَذَا تَأْوِيلُ قَوْلِ اللهِ: ﴿أَلاَ لَهُ الْخَلْقُ وَ الْأَمْرُ تَبَارَكَ اللهُ رَبُّ الْعَالَمِينَ﴾، فَأَقْبَلَ (عَلَيْهِ السَّلاَمُ) عَلَيَّ، وَ قَالَ: «هُوَ كَمَا أَسْرَرْتَ فِي نَفْسِكَ ﴿أَلاَ لَهُ الْخَلْقُ وَ الْأَمْرُ تَبَارَكَ اللهُ رَبُّ الْعَالَمِينَ﴾».

ខ្ញុំក៏បាននឹកក្នុងចិត្តថា៖ "នេះជាការបកស្រាយរបស់អាយ៉ាស៊ុ *[៧:៥៤] មិនអាចប្រកែកបានទេ ការបង្កើតនិងព្រះរាជបញ្ជាជាកម្មសិទ្ធិរបស់ព្រះអង្គ ។ សូមពរជ័យសិរីសួស្តីមានដល់អល់ឡោះហ្ស៊ី ម្ចាស់ពិភពទាំងពួង ។"* ព្រះអង្គ صلوات الله عليه والسلام បានបែរមករកខ្ញុំ ហើយមានវចនៈថា៖ "ដូចលោកលាក់ទុកក្នុងចិត្តមែនគឺ៖ *[៧:៥៤] មិនអាចប្រកែកបានទេ ការបង្កើតនិងព្រះរាជបញ្ជាជាកម្មសិទ្ធិរបស់ព្រះអង្គ ។ សូមពរជ័យសិរីសួស្តីមានដល់អល់ឡោះហ្ស៊ី ម្ចាស់ពិភពទាំងពួង ។"*

فَقُلْتُ: أَشْهَدُ أَنَّكَ حُجَّةُ اللهِ، وَ ابْنُ حُجَّتِهِ عَلَى عِبَادِهِ. (البرهان في تفسير القرآن ١ – الجزء : ٢ صفحة : ٥٥٩ الحديث : ٩٩/ ٣٩٣٢ ، الثاقب في المناقب – الجزء : ١ صفحة : ٥٦٤ الحديث : ٥٠٢)**

ខ្ញុំបានទូលថា៖ "ទូលបង្គំសូមប្តេជ្ញាថាព្រះអង្គ(صلوات الله عليه والسلام)ជាព្រះអាជ្ញាធរ(صلوات الله عليه والسلام)របស់អល់ឡោះហ្ទ៉ា(عزّ وجلّ) ជារាជបុត្ររបស់ព្រះរាជអាជ្ញាធរ(صلوات الله عليه والسلام)លើបាវអល់ឡោះហ្ទ៉ា(عزّ وجلّ)ទាំងអស់ ។" (الثاقب في المناقب: 564/ 502)

***

*٢/٥٤/٧ اَلْعَيَّاشِيُّ: عَنْ أَبِي جَعْفَرٍ، عَنْ رَجُلٍ، عَنْ أَبِي عَبْدِ اَللَّهِ (عَلَيْهِ اَلسَّلاَمُ)، قَالَ: «إِنَّ اَللَّهَ خَلَقَ اَلسَّمَاوَاتِ وَ اَلْأَرْضَ فِي سِتَّةِ أَيَّامٍ، فَالسَّنَةُ تَنْقُصُ سِتَّةَ أَيَّامٍ». (البرهان في تفسير القرآن – الجزء: ٣ الصفحة: ١٣ الحديث: ٩٩/ ٤٨٤٠ ، تفسير العيّاشي – الجزء: ٢ الصفحة: ١٢٠ الحديث: ٦)***

*7/54/2 អាល់-អ៊ៃយ៉ាស៊្ញី បានតំណាលតមកពី អាប៊ូ យ៉ាក់ហ្វារ ដែលបានតំណាលតមកពីបុរសម្នាក់ដែលបានតំណាលតមកពី អាប៊ូ អាប់ឌុលឡោះហ្វ(صلوات الله عليه والسلام) ។ ព្រះអង្គ(صلوات الله عليه والسلام)មានវចនៈថា៖ "អល់ឡោះហ្ទ៉ា(عزّ وجلّ)បានបង្កើតមេឃទាំងឡាយនិងដីក្នុងរយៈពេលប្រាំមួយថ្ងៃ ។ ដូច្នេះឯងបានជាឆ្នាំខ្វះប្រាំមួយថ្ងៃ (៦ ខែ មាន ២៩ ថ្ងៃ) ។" (تفسير العيّاشي 2: 120/ 6)50:38, 10:3-4

***

*٣/٥٤/٧ عَنِ اَلصَّبَّاحِ بْنِ سَيَابَةَ، عَنْ أَبِي جَعْفَرٍ (عَلَيْهِ اَلسَّلاَمُ)، قَالَ: إِنَّ اَللَّهَ خَلَقَ اَلشُّهُورَ اِثْنَيْ عَشَرَ شَهْراً، وَ هِيَ ثَلاَثُمِائَةٍ وَ سِتُّونَ يَوْماً، فَحَجَزَ عَنْهَا سِتَّةَ أَيَّامٍ خَلَقَ فِيهَا اَلسَّمَاوَاتِ وَ اَلْأَرْضَ، فَمِنْ ثَمَّ تَقَاصَرَتِ اَلشُّهُورُ». (البرهان في تفسير القرآن – الجزء: ٣ الصفحة: ١٣ الحديث: ٩٩/ ٤٨٤١ ، تفسير العيّاشي – الجزء: ٢ الصفحة: ١٢٠ الحديث: ٧)**

*7/54/3 រាយការណ៍តមកពី អាល់-ស្វ៉ាបាស្ហ ប៊ីន សាយ៉ាបាស្ហ តមកពី អាប៊ូ យ៉ាក់ហ្វារ(صلوات الله عليه والسلام) ដែលមានវចនៈថា៖ "អល់ឡោះហ្ទ៉ា(عزّ وجلّ)បានបង្កើតដប់ពីរខែ ។ ខែទាំងនេះមានបីរយហុកសិបថ្ងៃ ។ ព្រះអង្គ(عزّ وجلّ)បានបំបែកយកប្រាំមួយថ្ងៃចេញពីនោះ ។ ព្រះអង្គ(عزّ وجلّ)បានបង្កើតមេឃទាំងឡាយនិងដីក្នុងប្រាំមួយថ្ងៃនោះ ។ បន្ទាប់មកខែទាំងនោះខ្វះ (៦ ខែ មាន ២៩ ថ្ងៃ) ។" (تفسير العيّاشي 2: 120/ 7)10:3-4

***

*٤/٥٤/٧ عَنْهُ عَنْ عَبْدِ اللهِ بْنِ سِنَانٍ قَالَ سَمِعْتُ أَبَا عَبْدِ اللهِ (عَلَيْهِ السَّلاَمُ) يَقُولُ إِنَّ اللهَ خَلَقَ الْخَيْرَ يَوْمَ الْأَحَدِ وَ مَا كَانَ لِيَخْلُقَ الشَّرَّ قَبْلَ الْخَيْرِ وَ فِي يَوْمِ الْأَحَدِ وَ الْإِثْنَيْنِ خَلَقَ الْأَرَضِينَ وَ خَلَقَ أَقْوَاتَهَا فِي يَوْمِ الثَّلاَثَاءِ وَ خَلَقَ السَّمَاوَاتِ يَوْمَ الْأَرْبِعَاءِ وَ يَوْمَ الْخَمِيسِ وَ خَلَقَ أَقْوَاتَهَا يَوْمَ الْجُمُعَةِ وَ ذَلِكَ قَوْلُهُ عَزَّ وَ جَلَّ ﴿خَلَقَ السَّماواتِ وَ الْأَرْضَ وَ ما بَيْنَهُما فِي سِتَّةِ أَيَّامٍ﴾. (الكافي – الجزء : ٨ صفحة : ١٤٥ حديث : ١١٧)

*7/54/4 អាប់ឌុលឡោះហ្ទ៉ា ប៊ីន ស៊ីណានបានថាខ្ញុំបានឮ អាប៊ូ អាប់ឌុលឡោះហ្វ(صلوات الله عليه والسلام)មានវចនៈថា៖ "អល់ឡោះហ្ទ៉ា(عزّ وجلّ)បង្កើតអ្វីៗដែលល្អក្នុងថ្ងៃអាទិត្យ ។ ព្រះអង្គ(عزّ وجلّ)មិនបង្កើតអ្វីៗដែលអាក្រក់មុនអ្វីៗដែលល្អទេ ។ ព្រះអង្គ(عزّ وجلّ)បង្កើតផែនដីទាំងឡាយក្នុងថ្ងៃអាទិត្យនិងថ្ងៃចន្ទ ព្រះអង្គ(عزّ وجلّ)បង្កើតគ្រឿងទ្រទ្រង់វាក្នុងថ្ងៃអង្គារ ។ ព្រះអង្គ(عزّ وجلّ)បង្កើតមេឃទាំងឡាយក្នុងថ្ងៃពុធនិងថ្ងៃព្រហស្បត្តិ៍ ហើយព្រះអង្គ(عزّ وجلّ)បង្កើតគ្រឿងទ្រទ្រង់វាក្នុងថ្ងៃសុក្រ ។ នេះគឺព្រះបន្ទូលរបស់អល់ឡោះហ្ទ៉ា(عزّ وجلّ) *[៣២:៤] បង្កើតមេឃនិងដីនិងអ្វីៗដែលមាននៅក្នុងចន្លោះទាំងពីរនោះក្នុងប្រាំមួយថ្ងៃ ។"* (الكافي 8: 145/ 117)11:7

***

*٥/٥٤/٧ وَ عَنْهُ، قَالَ: حَدَّثَنَا مُحَمَّدُ بْنُ اَلْحَسَنِ بْنِ أَحْمَدَ بْنِ اَلْوَلِيدِ (رَحِمَهُ اَللَّهُ)، قَالَ: حَدَّثَنَا مُحَمَّدُ بْنُ اَلْحَسَنِ اَلصَّفَّارُ، عَنْ عَلِيِّ بْنِ إِسْمَاعِيلَ، عَنْ حَمَّادِ بْنِ عِيسَى، عَنْ إِبْرَاهِيمَ بْنِ عُمَرَ اَلْيَمَانِيِّ ، عَنْ أَبِي اَلطُّفَيْلِ، عَنْ أَبِي جَعْفَرٍ، عَنْ عَلِيِّ بْنِ اَلْحُسَيْنِ (عَلَيْهِمَا اَلسَّلاَمُ) قَالَ: «إِنَّ اَللَّهَ عَزَّ وَ جَلَّ خَلَقَ اَلْعَرْشَ أَرْبَاعاً، لَمْ يَخْلُقْ قَبْلَهُ إِلاَّ ثَلاَثَةَ أَشْيَاءَ: اَلْهَوَاءَ، وَ اَلْقَلَمَ، وَ اَلنُّورَ، ثُمَّ خَلَقَهُ مِنْ أَنْوَارٍ مُخْتَلِفَةٍ، فَمِنْ ذَلِكَ اَلنُّورِ نُورٌ أَخْضَرُ اِخْضَرَّتْ مِنْهُ اَلْخُضْرَةُ، وَ نُورٌ أَصْفَرُ اِصْفَرَّتْ مِنْهُ اَلصُّفْرَةُ، وَ نُورٌ أَحْمَرُ اِحْمَرَّتْ مِنْهُ اَلْحُمْرَةُ، وَ نُورٌ أَبْيَضُ وَ هُوَ نُورُ

اَلْأَنْوَارِ، وَ مِنْهُ ضَوْءُ اَلنَّهَارِ.

*7/54/5 [...] អាប៊ូ យ៉ាក់ហ្វារ صلوات الله عليه والسلام បានតំណាលតមកពី អ៊ុលី ប៊ិន អាល់-ហ៊្វសែន៏ صلوات الله عليه والسلام ដែលមានវចនៈថា៖ "ព្រះរាជបល្ល័ង្កជាវត្ថុទីបួនដែលអល់ឡោះហ៊្វ عزّ وجلّ បានបង្កើតមក ។ ព្រះអង្គ عزّ وجلّ បានបង្កើតមុនព្រះរាជបល្ល័ង្កនេះតែបីវត្ថុទេ គឺ៖ ខ្យល់អាកាស, ប៉ាកកា និងរស្មី ។ បន្ទាប់ពីនោះមកព្រះអង្គ عزّ وجلّ បានបង្កើតរស្មី នានា ។ ក្នុងចំណោមរស្មីទាំងនោះមានរស្មីបៃតង ពណ៌បៃតងចេញមកពីរស្មីនេះឯង ។ រស្មីលឿង ពណ៌ លឿងចេញមកពីរស្មីនេះឯង ។ រស្មីក្រហម ពណ៌ក្រហមចេញមកពីរស្មីនេះឯង ។ រស្មីស នេះគឺរស្មីរបស់រស្មីទាំងឡាយ ។ ការបំភ្លឺពេលថ្ងៃមកពីរស្មីនេះឯង ។

ثُمَّ جَعَلَهُ سَبْعِينَ أَلْفَ طَبَقٍ، غِلَظُ كُلِّ طَبَقٍ كَأَوَّلِ اَلْعَرْشِ إِلَى أَسْفَلِ اَلسَّافِلِينَ، لَيْسَ مِنْ ذَلِكَ طَبَقٌ إِلاَّ يُسَبِّحُ بِحَمْدِ رَبِّهِ، وَ يُقَدِّسُهُ بِأَصْوَاتٍ مُخْتَلِفَةٍ، وَ أَلسِنَةٍ غَيْرِ مُشْتَبِهَةٍ، وَ لَوْ أُذِنَ لِلِسَانٍ مِنْهَا فَأَسْمَعَ شَيْئاً مِمَّا تَحْتَهُ لَهَدَمَ اَلْجِبَالَ وَ اَلْمَدَائِنَ وَ اَلْحُصُونَ، وَ لَخَسَفَ اَلْبِحَارَ، وَ لَأَهْلَكَ مَا دُونَهُ.

បន្ទាប់មកអល់ឡោះហ៊្វ عزّ وجلّ បានធ្វើឲ្យមានចិតសិបពាន់ស្រទាប់ ។ កម្រាស់ស្រទាប់នីមួយៗស្មើកំពូលព្រះរាជបល្ល័ង្កដល់បាតព្រះរាជបល្ល័ង្ក ។ ក្នុងស្រទាប់នោះសព្វសត្វថ្វាយថោមនាការចំពោះព្រះម្ចាស់ عزّ وجلّ ខ្លួនលើកតម្កើងព្រះសន្តភាពព្រះម្ចាស់ عزّ وجلّ ខ្លួនដោយសម្លេងនិងភាសាផ្សេងៗដែលខុសៗគ្នា ។ បើភាសាណាមួយលេចឮពីស្រទាប់នោះ អ្វីៗដែលនៅខាងក្រោម ភ្នំ ស្រុកនានានិងបន្ទាយនឹងបាក់បែក សមុទ្រទាំងឡាយនឹងជន់ ហើយអ្វីៗក្រៅពីនោះនឹងវិនាស ។

لَهُ ثَمَانِيَةُ أَرْكَانٍ، عَلَى كُلِّ رُكْنٍ مِنْهَا مِنَ اَلْمَلاَئِكَةِ مَا لاَ يُحْصِي عَدَدَهُمْ إِلاَّ اَللَّهُ عَزَّ وَ جَلَّ، يُسَبِّحُونَ فِي اَللَّيْلِ وَ اَلنَّهَارِ لاَ يَفْتُرُونَ، وَ لَوْ أَحَسَّ شَيْءٌ مِمَّا فَوْقَهُ مَا قَامَ لِذَلِكَ طَرْفَةَ عَيْنٍ، بَيْنَهُ وَ بَيْنَ اَلْإِحْسَاسِ اَلْجَبَرُوتُ وَ اَلْكِبْرِيَاءُ وَ اَلْعَظَمَةُ وَ اَلْقُدُسُ وَ اَلرَّحْمَةُ ثُمَّ اَلْعِلْمُ، وَ لَيْسَ وَرَاءَ هَذَا مَقَالٌ». (البرهان في تفسير القرآن - اَلْجُزْء: ٣ صَفْحَة: ٨١ حَدِيث: ٩٩ /٥٠١٦ ، التوحيد - اَلْجُزْء: ١ صَفْحَة: ٣٢٤ حَدِيث: ١)**

ព្រះរាជបល្ល័ង្កមានប្រាំបីជ្រុង (គឺកន្លែង) ។ លើជ្រុងនីមួយៗមានទេវតារាប់មិនអស់ មានតែអល់ឡោះហ៊្វ عزّ وجلّ ទេដែលស្គាល់ចំនួនទេវតាទាំងនោះ ។ ពួកទេវតាទាំងនោះថ្វាយសេចក្ដីរុងរឿងទាំងយប់ទាំងថ្ងៃ មិនស្រាកស្រាន្តឡើយ ។ បើមានអ្វីមួយប្រសើរជាងអ្វីដែលនៅពីលើព្រះរាជបល្ល័ង្កនោះ ច្បាស់ជាពួកគេមិនអាចឈរកេវាបានទេ ទោះបីមួយប៉ប្រិចភ្នែកក៏ដោយ នៅចន្លោះអល់ឡោះហ៊្វ عزّ وجلّ និងអាការដឹងដោយវិញ្ញាណព្រះមហិទ្ធិឫទ្ធិ ព្រះវិសាលភាព ព្រះវិពោចនភាព ព្រះសន្តភាព ព្រះមេត្តាធម៌និងព្រះអភិញ្ញា ។ មិនមានអ្វី[លើសពីនេះ]ទេនៅពីក្រោយសេចក្ដីថ្លែងនេះ ។" (التوحيد: 324 /1)11:7

***

មើលអធិប្បាយស៊ូរ៉ោះត៏ ១១ (ហ៊្វូដ) ហ្គាឌ្វីស្ស 11/7/8 ។

***

*٦/٥٤/٧ [أبو عمرو الخوري] قرأت في فضائل فاطمة بنت رسول الله صلى الله عليه ورضي عنها تأليف أبي القاسم المنيعي عبد الله بن محمد بن عبد العزيز، حدثنا يحيى بن جعفر الواسطي، قال: حدثنا كثير بن هشام، قال: حدثنا عيسى، يعني ابن إبراهيم الهاشمي، قال: حدثنا الثمالي، قال: سمعت علي بن الحسين يقول: لما دنا ولادة فاطمة أمر رسول الله صلى الله عليه ابنة عميس وام أيمن أن ائتيا فاطمة، فاقرئا عندها آية الكرسي، و * إِنَّ رَبَّكُمُ اللَّهُ الَّذِي خَلَقَ السَّمَاوَاتِ وَالْأَرْضَ فِي سِتَّةِ أَيَّامٍ ثُمَّ اسْتَوَى عَلَى الْعَرْشِ يُغْشِي اللَّيْلَ النَّهَارَ يَطْلُبُهُ حَثِيثًا وَالشَّمْسَ وَالْقَمَرَ وَالنُّجُومَ مُسَخَّرَاتٍ بِأَمْرِهِ أَلَا لَهُ الْخَلْقُ وَالْأَمْرُ تَبَارَكَ اللَّهُ رَبُّ الْعَالَمِينَ * وعوذاها بالمعوذتين. (تفسير أبي حمزة الثمالي - الجزء : ١ صفحة : ٣٦٨ الحديث : ٣٧٩)

*7/54/6 [...] អាប៊ូ អ៊ុំរ៉ូ អាល់-យូរី បានអាននៅក្នុង[សាត្រា] *គុណសម្បត្តិពិសេសរបស់ហ្វាទីម៉ាស្ស៊ុ* سلام الله عليها *ព្រះ រាជបុត្រីរបស់រ៉ស៊ូលុលឡោះហ៊្វ* صلى الله عليه وآله وسلم ។ លោកបានពេញចិត្តនឹងអ្នកនិពន្ធ អាប៊ូ អាល់-ក៏ស៊ីម អាល់-ម៉ានីអ៊ី អ៊ុប់ឌុលឡោះហ្វ ប៊ិន មូហ៊ាំម៉ាដ្ឌ ប៊ិន អ៊ុប់ឌុល អ៊ុស៊ីស ។ យ៉ាស៊ុយ៉ា ប៊ិន យ៉ាក់ហ្វារ អាល់-វ៉ាស៊ីទ្ទីបាន តំណាលប្រាប់យើងថា កាស៊្ទៀរ ប៊ិន ហ៊ុស្សាំ បានតំណាលថា អ៊ីសា ពោលគឺ អ៊ីបនូ អ៊ីបរ៉ហ៊ីម អាល់-ហ្វាស្ស៊ីមី បានតំណាលថា អាល់-ស៊្ទម៉ាលី បានតំណាលថាខ្ញុំបានឮ អាលី ប៊ិន អាល់-ហ៊ូសៃន៍ صلوات الله عليه والسلام មានវចនៈថា៖ "កាលហ្វាទីម៉ាស្ស៊ុ سلام الله عليها ប្រសូតមក រ៉ស៊ូលុលឡោះហ៊្វ صلى الله عليه وآله وسلم បានបញ្ជាឲ្យកូនស្រីរបស់អ៊ុម៉ែស៍ និង អ៊ូម អៃម៉ាន ទៅយកហ្វាទីម៉ាស្ស៊ុ سلام الله عليها មកឲ្យព្រះអង្គ صلى الله عليه وآله وسلم ។ ព្រះអង្គ صلى الله عليه وآله وسلم បានសូត្រលើព្រះនាង سلام الله عليها *អាយ៉ាស្ស៊ុ អាល់-គូរស៊ី* (ស៊ូរ៉ោះត៍ ២ អាយ៉ាស្ស៊ុ ២៥៥-២៥៧) និង *[៧:៥៤] ម្ចាស់ពួកអ្នកគឺអល់ឡោះហ្វ ព្រះអង្គបានបង្កើតមេឃទាំងឡាយនិងដីក្នុងរយៈពេលប្រាំមួយថ្ងៃ បន្ទាប់មកព្រះអង្គបានសម្តែងព្រះរាជឆន្ទៈព្រះអង្គលើព្រះរាជបល្ល័ង្ក ។ ព្រះអង្គគ្របដណ្តប់ពេលថ្ងៃដោយពេលរាត្រីដែលប្រដេញតាមវាយ៉ាងស្វិតស្វាញ ។ [អល់ឡោះហ្វបានបង្កើត]ដួងអាទិត្យ ដួងចន្ទនិងដួងតារាទាំងឡាយដែលគោរពតាមព្រះរាជបញ្ជាព្រះអង្គ ។ មិនអាចប្រកែកបានទេ ការបង្កើតនិងព្រះរាជបញ្ជាជាកម្មសិទ្ធិរបស់ព្រះអង្គ ។ សូមពរជ័យសិរីសួស្តីមានដល់អល់ឡោះហ្វ ម្ចាស់ពិភពទាំងពួង ។* ហើយព្រះអង្គ صلى الله عليه وآله وسلم បានបួងសួងសូមជម្រក អាស្រ័យឲ្យព្រះនាង سلام الله عليها ដោយ អាល់-មូអៅវីស៊ាតែន៍ (الْمُعَوِّذَتَيْنِ គឺ ស៊ូរ៉ោះត៍ អាល់-ហ្វាឡាក់ និង ស៊ូរ៉ោះត៍ អាន់-ណាស់) ។" (تفسير أبي حمزة الثمالي ហ្វាឌីស្ស ៣៧៩)114:1-6

ٱدْعُواْ رَبَّكُمْ تَضَرُّعًا وَخُفْيَةً ۚ إِنَّهُۥ لَا يُحِبُّ ٱلْمُعْتَدِينَ ﴿٥٥﴾

៥៥. ចូរពួកអ្នកបួងសួងម្ចាស់ពួកអ្នកដោយដាក់ខ្លួននិងដោយសម្ងាត់ (ដោយស្ងៀងស្ងាត់) ។ ព្រះអង្គមិនសព្វព្រះហឫទ័យជនបំពារបំពានទេ ។

وَلَا تُفْسِدُواْ فِى ٱلْأَرْضِ بَعْدَ إِصْلَـٰحِهَا وَٱدْعُوهُ خَوْفًا وَطَمَعًا ۚ إِنَّ رَحْمَتَ ٱللَّهِ قَرِيبٌ مِّنَ ٱلْمُحْسِنِينَ ﴿٥٦﴾

៥៦. ចូរពួកអ្នកកុំបង្កវិនាសនៅលើផែនដី ក្រោយពីវាត្រូវបានកែតម្រូវហើយ ។ ចូរពួកអ្នកបួងសួងព្រះអង្គដោយក្រែងខ្លាចនិងដោយសង្ឃឹម ។ ព្រះមេត្តាករុណាអល់ឡោះហ្វនៅក្បែរបណ្តាអ្នកប្រព្រឹត្តល្អ ។

អធិប្បាយអាយ៉ាស្ស៊ុ ៥៥-៥៦

٧/٥٥-٥٦/١ وَ عَنْهُ: عَنْ مُحَمَّدِ بْنِ يَحْيَى، عَنْ أَحْمَدَ بْنِ مُحَمَّدِ بْنِ عِيسَى، عَنْ مُحَمَّدِ بْنِ خَالِدٍ، وَ الْحُسَيْنِ بْنِ سَعِيدٍ، جَمِيعاً، عَنِ النَّضْرِ بْنِ سُوَيْدٍ، عَنْ يَحْيَى الْحَلَبِيِّ، عَنْ أَبِي خَالِدٍ، عَنْ مَرْوَكٍ بَيَّاعِ اللُّؤْلُؤِ، عَمَّنْ ذَكَرَهُ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، قَالَ: «ذَكَرَ الرَّغْبَةَ وَ أَبْرَزَ [بَاطِنَ] رَاحَتَيْهِ إِلَى السَّمَاءِ، وَ هَكَذَا الرَّهْبَةُ: وَ جَعَلَ ظَهْرَ كَفَّيْهِ إِلَى السَّمَاءِ، وَ هَكَذَا التَّضَرُّعُ: وَ حَرَّكَ أَصَابِعَهُ يَمِيناً وَ شِمَالاً، وَ هَكَذَا التَّبَتُّلُ: وَ يَرْفَعُ أَصَابِعَهُ مَرَّةً، وَ يَضَعُهَا مَرَّةً، وَ هَكَذَا الاِبْتِهَالُ وَ مَدَّ يَدَهُ تِلْقَاءَ وَجْهِهِ إِلَى الْقِبْلَةِ، وَ لاَ يَبْتَهِلُ حَتَّى تَجْرِيَ الدَّمْعَةُ».
(الكافي : الجزء ٢ الصفحة ٣٤٨ الحديث ٣ ، البرهان في تفسير القرآن: الجزء: ٥ صفحات: ٥١٨ الحديث: ٩٩ /١١١٦٤)**

7/55-56/1 [...] អាប៊ូ អ៊ុប់ឌុលឡោះហ្វ صلوات الله عليه والسلام មានវចនៈថា៖ "ព្រះអង្គ صلوات الله عليه والسلام ថាសេចក្តីប្រាថ្នាហើយបង្ហាញបាតដៃទៅរកមេឃ ។ សេចក្តីខ្លាចក្រែងដោយគោរព (الرَّهْبَةُ) គឺដូចនេះ" - ព្រះអង្គ صلوات الله عليه والسلام ដាក់ខ្នងព្រះហត្ថព្រះអង្គ صلوات الله عليه والسلام ទៅរកមេឃ ។ "អង្វរករ គឺដូចនេះ" - ព្រះអង្គ صلوات الله عليه والسلام កម្រើកម្រាមដៃទាំងឡាយរបស់ព្រះអង្គ صلوات الله عليه والسلام ទៅខាងស្តាំនិងទៅខាងឆ្វេង ។ "ប្រគល់កាយថ្វាយចិត្ត (التَّبَتُّلُ)" គឺដូចនេះ" - ព្រះអង្គ صلوات الله عليه والسلام លើកម្រាមដៃទាំងឡាយរបស់ព្រះអង្គ صلوات الله عليه والسلام ឡើងមួយដង ហើយដាក់មកវិញមួយដង ។ "ការបន់ស្រន់

(الاِبْتِهَالُ) គឺដូចនេះ" - ព្រះអង្គ صلوات الله عليه والسلام លាតព្រះហត្ថព្រះអង្គ صلوات الله عليه والسلام ហើយបែរព្រះភក្ត្រព្រះអង្គ صلوات الله عليه والسلام ទៅរកគ្ឹបឡាស់ ។ ទាល់តែមានទឹកភ្នែកហូរទើបមានការបន់ស្រន់ ។" (الكافي 2: 348/ 3)73:7-8

***

*٧/٥٥-٥٦/٢ عَلِيُّ بْنُ إِبْرَاهِيمَ عَنْ أَبِيهِ عَنْ حَمَّادٍ عَنْ حَرِيزٍ عَنْ مُحَمَّدِ بْنِ مُسْلِمٍ وَ زُرَارَةَ قَالَا قُلْنَا لِأَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلَامُ) كَيْفَ الْمَسْأَلَةُ إِلَى اللَّهِ تَبَارَكَ وَ تَعَالَى قَالَ تَبْسُطُ كَفَّيْكَ قُلْنَا كَيْفَ الِاسْتِعَاذَةُ قَالَ تُفْضِي بِكَفَّيْكَ وَ التَّبَتُّلُ الْإِيمَاءُ بِالْإِصْبَعِ وَ التَّضَرُّعُ تَحْرِيكُ الْإِصْبَعِ وَ الِابْتِهَالُ أَنْ تَمُدَّ يَدَيْكَ جَمِيعاً. (الكافي – الجزء : ٢ صفحة : ٤٨١ الحديث : ٧)

*7/55-56/2 [...] រាយការណ៍មកពី មូហ៊ាំម៉ាដ់ ប៊ិន មុស្លីម និង ស៊ូរ៉ោះត៍ ដែលបានថាយើងបានទូលអាប៊ូ អាប់ឌុលឡោះហ៍ صلوات الله عليه والسلام ថា៖ "តើ[គប្បី]សូមអល់ឡោះហ៍ عزوجل ដូចម្ដេច[ដែលត្រឹមត្រូវ] ?" ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "លាតបាតដៃ ។" យើងបានទូលថា៖ "តើ[គប្បី]សូមជម្រកពីអល់ឡោះហ៍ صلوات الله عليه والسلام ដូចម្ដេច[ដែលត្រឹមត្រូវ] ?" ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "បង្ហាញបាតដៃ ។ ប្រគល់កាយថ្វាយចិត្តគឺធ្វើកាយវិការដោយម្រាមដៃ ។ អង្វរករគឺកម្រើកម្រាមដៃ ។ បន់ស្រន់គឺលោកលាតសន្ធឹងដៃលោក ។(الكافي 2: 481/ 7)

***

*٧/٥٥-٥٦/٣ مُحَمَّدُ بْنُ يَحْيَى عَنْ أَحْمَدَ بْنِ مُحَمَّدِ بْنِ عِيسَى عَنْ أَبِي هَمَّامٍ إِسْمَاعِيلَ بْنِ هَمَّامٍ عَنْ أَبِي الْحَسَنِ الرِّضَا (عَلَيْهِ السَّلَامُ) قَالَ دَعْوَةُ الْعَبْدِ سِرّاً دَعْوَةً وَاحِدَةً تَعْدِلُ سَبْعِينَ دَعْوَةً عَلَانِيَةً .

*7/55-56/3 [...] រាយការណ៍ដោយ អាប៊ូ ហ៊ាំមុាំ អ៊ីសម៉ាអ៊ីល ប៊ិន ហ៊ាំមុាំ តមកពី អាប៊ូ អាល់-ហ៊ាសាន់ صلوات الله عليه والسلام អាល់-រីដ៏ صلوات الله عليه والسلام ដែលមានវចនៈថា៖ "ការបួងសួងស្ងាត់ៗមួយរបស់បាវស្មើនឹងការបួងសួងឮៗចិតសិប ។

وَ فِي رِوَايَةٍ أُخْرَى دَعْوَةٌ تُخْفِيهَا أَفْضَلُ عِنْدَ اللَّهِ مِنْ سَبْعِينَ دَعْوَةً تُظْهِرُهَا . (الكافي – الجزء : ٢ صفحة : ٤٧٦ الحديث : ١)

[ព្រះអង្គ صلوات الله عليه والسلام មានវចនៈនៅក្នុងសេចក្ដីរាយការណ៍មួយទៀតថា៖] "សម្រាប់អល់ឡោះហ៍ عزوجل ការបួងសួងដោយលាក់បាំងខ្ពស់ជាងការបួងសួងឲ្យគេឃើញចិតសិប ។" (الكافي 2: 476/ 1)

***

٧/٥٥-٥٦/٤ وَ عَنْهُ عَنْ مُحَمَّدِ بْنِ عَلِيٍّ عَنِ ابْنِ مُسْكَانَ عَنْ مُيَسِّرٍ عَنْ أَبِي جَعْفَرٍ (عَلَيْهِ السَّلَامُ) قَالَ قُلْتُ قَوْلُ اللَّهِ عَزَّ وَ جَلَّ وَ لا تُفْسِدُوا فِي الْأَرْضِ بَعْدَ إِصْلاحِها قَالَ فَقَالَ يَا مُيَسِّرُ إِنَّ الْأَرْضَ كَانَتْ فَاسِدَةً فَأَصْلَحَهَا اللَّهُ عَزَّ وَ جَلَّ بِنَبِيِّهِ (صلى الله عليه وآله) فَقَالَ وَ لا تُفْسِدُوا فِي الْأَرْضِ بَعْدَ إِصْلاحِها. (الكافي – الجزء : ٨ صفحة : ٥٨ الحديث : ٢٠)

7/55-56/4 [...] គេបានសួរអាប៊ូ យ៉ាក់ហ្វារ صلوات الله عليه والسلام អំពីព្រះបន្ទូលអល់ឡោះហ៍ عزوجل *[៧:៥៦] ចូរពួកអ្នកកុំបង្កវិនាសនៅលើផែនដី ក្រោយពីវាត្រូវបានកែតម្រូវហើយ ។* ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "មូយ៉ាសៀរអើយ ! ផែនដីតែងតែគ្មានសណ្ដាប់ធ្នាប់ ។ ដូច្នេះអល់ឡោះហ៍ عزوجل បានកែតម្រូវវាដោយព្រះសាស្ដា صلى الله عليه وآله وسلم ព្រះអង្គ عزوجل ។ ដូច្នេះឯងបានជាព្រះអង្គ عزوجل មានព្រះរាជបន្ទូលថា៖ *[៧:៥៦] ចូរពួកអ្នកកុំបង្កវិនាសនៅលើផែនដី ក្រោយពីវាត្រូវបានកែតម្រូវហើយ ។"* (الكافي 8: 58/ 20)

***

*٧/٥٥-٥٦/٥ عِدَّةٌ مِنْ أَصْحَابِنَا عَنْ أَحْمَدَ بْنِ مُحَمَّدِ بْنِ عِيسَى عَنِ الْحُسَيْنِ بْنِ سَعِيدٍ عَنْ فَضَالَةَ بْنِ أَيُّوبَ عَنْ عَبْدِ اللَّهِ بْنِ بُكَيْرٍ عَنْ أَبِي بَصِيرٍ عَنْ أَبِي جَعْفَرٍ (عَلَيْهِ السَّلَامُ) قَالَ قَالَ رَسُولُ اللَّهِ (صلى الله عليه و آله) سِبَابُ الْمُؤْمِنِ فُسُوقٌ وَ قِتَالُهُ كُفْرٌ وَ أَكْلُ لَحْمِهِ مَعْصِيَةٌ وَ حُرْمَةُ مَالِهِ كَحُرْمَةِ دَمِهِ . (الكافي – المجلد : ٢ صفحة : ٣٥٩ الحديث : ٢)

*7/55-56/5 [...] រាយការណ៍មកពី អាប៊ូ បាស្សៀរ តមកពី អាប៊ូ យ៉ាក់ហ្វារ صلوات الله عليه والسلام ដែលមានវចនៈថា រ៉ស៊ូលុលឡោះហ៍ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "ជេរប្រមាថមុមីនជាប្រការបង្កវិនាស សម្លាប់មុមីនជាអំពើក្បត់

សាសនា ស៊ីសាច់មុមីន (គឺនិយាយបង្ការ៉ាច់មុមីន) ជាអំពើល្មើសបង្ការ៉ាប់ ទ្រព្យរបស់មុមីនមានពិសិដ្ឋភាពដូចឈាមមុមីននោះដែរ ។" (الكافي 2: 2/ 359)

***

*٧/٥٥-٥٦/٦ سَهْلُ بْنُ زِيَادٍ عَنِ ابْنِ مَحْبُوبٍ عَنْ أَبِي حَمْزَةَ الثُّمَالِيِّ عَنْ أَبِي جَعْفَرٍ (عَلَيْهِ السَّلاَمُ) قَالَ قَالَ رَسُولُ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) لِرَجُلٍ أَنْتَ وَ مَالُكَ لِأَبِيكَ ثُمَّ قَالَ أَبُو جَعْفَرٍ (عَلَيْهِ السَّلاَمُ) وَ مَا أُحِبُّ لَهُ أَنْ يَأْخُذَ مِنْ مَالِ ابْنِهِ إِلَّا مَا احْتَاجَ إِلَيْهِ مِمَّا لَا بُدَّ مِنْهُ إِنَّ اللَّهَ عَزَّ وَ جَلَّ لَا يُحِبُّ الْفَسَادَ . (الكافي – المجلد : ٥ صفحة : ١٣٥ الحديث : ٣)

*7/55-56/6 [...] រាយការណ៍មកពី អាប៊ូ ហ្ជាំស្ការ៉ ស៊ុ អាល់-ស្ស៊ីម៉ាលី តមកពី អាប៊ូ យ៉ាកុ៌ហ្ជារ ﷺ ដែលមានវចន:ថារ៉ាស៊ូលុលឡោះ ﷺ បានប្រាប់បុរសម្នាក់ថា៖ "លោកនិងទ្រព្យបានទៅឪពុកលោក ។" បន្ទាប់មក អាប៊ូ យ៉ាកុ៌ហ្ជារ ﷺ មានវចន:ថា៖ "ខ្ញុំមិនចូលចិត្តទេដែលគាត់យកទ្រព្យពីកូនប្រុសគាត់ លើកលែងតែអ្វីដែលគាត់ត្រូវការប៉ុណ្ណោះ អ្វីដែលចាំបាច់ ។" អល់ឡោះ ﷻ មិនសព្វព្រះហឫទ័យបុគ្គលបង្ការ៉ាវិនាសទេ ។" (الكافي 5: 3/ 135)

***

*٧/٥٥-٥٦/٧ عِدَّةٌ مِنْ أَصْحَابِنَا عَنْ أَحْمَدَ بْنِ أَبِي عَبْدِ اللَّهِ عَنْ إِبْرَاهِيمَ بْنِ مُحَمَّدٍ الْهَمَذَانِيِّ قَالَ كَتَبْتُ إِلَى أَبِي جَعْفَرٍ (عَلَيْهِ السَّلاَمُ) فِي التَّزْوِيجِ فَأَتَانِي كِتَابُهُ بِخَطِّهِ قَالَ رَسُولُ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) إِذَا جَاءَكُمْ مَنْ تَرْضَوْنَ خُلُقَهُ وَ دِينَهُ فَزَوِّجُوهُ إِلَّا تَفْعَلُوهُ تَكُنْ فِتْنَةٌ فِي الْأَرْضِ وَ فَسَادٌ كَبِيرٌ . (الكافي – المجلد : ٥ صفحة : ٣٤٧ الحديث : ٣)

*7/55-56/7 [...] រាយការណ៍មកពី អ៊ីបរ៉ហ្ជីម ប៊ិន មូហ្ជាំម៉ាដ្ (អាល់-ហ្ជាម៉ាស្ការ៉ នី ដែលបានថាខ្ញុំបានសរសេរសំបុត្រទៅ អាប៊ូ យ៉ាកុ៌ហ្ជារ ﷺ សួររឿងអាពាហ៌ពិពាហ៌ ។ ព្រះអង្គ ﷺ បានសរសេរតបខ្ញុំវិញ ផ្ទាល់ដៃថារ៉ាស៊ូលុលឡោះ ﷺ មានព្រះវចន:ថា៖ "កាលណាបុគ្គលនីមួយមករកលោកដោយមានរបៀបរបបនិងសាសនាដែលលោកចូលចិត្ត កាលនោះចូរលោករៀបអាពាហ៌ពិពាហ៌[កូនស្រី]ឲ្យបុគ្គលនោះចុះ ឬបើលោកមិនរៀបអាពាហ៌ពិពាហ៌ឲ្យទេ នឹងកើតមានជម្លោះនៅផែនដីនិងការបង្ការ៉ាវិនាសធំ ។" (الكافي 5: 3/ 347)

وَهُوَ ٱلَّذِى يُرْسِلُ ٱلرِّيَٰحَ بُشْرًۢا بَيْنَ يَدَىْ رَحْمَتِهِۦ ۖ حَتَّىٰٓ إِذَآ أَقَلَّتْ سَحَابًا ثِقَالًا سُقْنَٰهُ لِبَلَدٍ مَّيِّتٍ فَأَنزَلْنَا بِهِ ٱلْمَآءَ فَأَخْرَجْنَا بِهِۦ مِن كُلِّ ٱلثَّمَرَٰتِ ۚ كَذَٰلِكَ نُخْرِجُ ٱلْمَوْتَىٰ لَعَلَّكُمْ تَذَكَّرُونَ ﴿٥٧﴾

៥៧. ព្រះអង្គជាអ្នកបញ្ជូនខ្យល់មក ដែលប្រាប់ឲ្យដឹងព្រះមេត្តាធម៌ព្រះអង្គជាមុន ។ លុះវាមានពពកទឹកធំៗយើងនឹងនាំវាទៅឯតំបន់មួយដែលបានស្លាប់ទៅហើយ ។ យើងបង្ហូរទឹកពីពពកនោះ យើងធ្វើឲ្យមានផលានុផលគ្រប់យ៉ាងចេញមកដោយសារទឹកនោះ ។ បែបនេះឯងដែលយើងនឹងធ្វើឲ្យអ្វីដែលស្លាប់ទៅហើយដើរ (ដើម្បីពួកអ្នកនឹងយកចិត្តទុកដាក់ ។

وَٱلْبَلَدُ ٱلطَّيِّبُ يَخْرُجُ نَبَاتُهُۥ بِإِذْنِ رَبِّهِۦ ۖ وَٱلَّذِى خَبُثَ لَا يَخْرُجُ إِلَّا نَكِدًا ۚ كَذَٰلِكَ نُصَرِّفُ ٱلْءَايَٰتِ لِقَوْمٍ يَشْكُرُونَ ﴿٥٨﴾

៥៨. តំបន់ល្អ (ដូងចិត្ត) រុក្ខជាតិ[ល្អ]ដុះឡើងអាស្រ័យការអនុញ្ញាតរបស់ម្ចាស់វា (គឺដោយសារព្រះឆន្ទ: អល់ឡោះ) ។ រីឯតំបន់អាក្រក់ (គឺហ៊ានហោចដោយសារអំពើបាបកម្ម) មានរុក្ខជាតិដុះចេញមកដោយកម្រ (គឺខូច យកជាការមិនបាន អំពើទុច្ចរិត ឧក្រិដ្ឋកម្ម) ។ បែបនេះឯងដែលយើងអធិប្បាយបណ្តាព្រះសញ្ញា[និងព្រះរាជឱ្ការ]សម្រាប់ជនកតញ្ញូ ។

អធិប្បាយអាយ៉ាស់ ៥៧-៥៨

٧/٥٧–١/٥٨ عَلِيُّ بْنُ إِبْرَاهِيمَ، عَنْ أَبِيهِ، عَنِ ابْنِ أَبِي عُمَيْرٍ، عَنْ هِشَامِ بْنِ سَالِمٍ، عَنْ أَبِي حَمْزَةَ، قَالَ: سَمِعْتُ عَلِيَّ بْنَ الْحُسَيْنِ (عليه السلام) يَقُولُ: «عَجَبٌ كُلُّ الْعَجَبِ لِمَنْ أَنْكَرَ الْمَوْتَ وَ هُوَ يَرَى مَنْ يَمُوتُ كُلَّ يَوْمٍ وَ لَيْلَةٍ، وَ الْعَجَبُ كُلُّ الْعَجَبِ لِمَنْ أَنْكَرَ النَّشْأَةَ الْأُخْرَى وَ هُوَ يَرَى النَّشْأَةَ الْأُولَى». (الكافي – الجزء : ٣ صفحة : ٢٥٨ الحديث : ٢٨)

7/57-58/1 [...] អ្ហ្ម៉ាលី ប៊ិន អាល់-ហ្ស៊ីសៃន៑ صلوات الله عليه والسلام មានវចន:ថា៖ "ចម្លែកមែនបុគ្គលដែលបដិសេធការស្លាប់ ខណ:ដែលខ្លួនឃើញមនុស្សស្លាប់រៀងរាល់ថ្ងៃយប់ ។ ដូច្នេះដែរ បុគ្គលដែលបដិសេធជីវិតក្រោយ (គឺការរស់ឡើងវិញ) ខណ:ដែលកំពុងមើលឃើញជីវិតលោកនេះ ។" (الكافي 3: 258/ 28)

***

٧/٥٧–٢/٥٨ مُحَمَّدُ بْنُ يَحْيَى عَنْ أَحْمَدَ بْنِ مُحَمَّدِ بْنِ عِيسَى عَنِ الْحَسَنِ بْنِ مَحْبُوبٍ عَنْ عَلِيِّ بْنِ رِئَابٍ وَ هِشَامِ بْنِ سَالِمٍ عَنْ أَبِي بَصِيرٍ قَالَ سَأَلْتُ أَبَا جَعْفَرٍ (عَلَيْهِ السَّلاَمُ) عَنِ الرِّيَاحِ الْأَرْبَعِ الشَّمَالِ وَ الْجَنُوبِ وَ الصَّبَا وَ الدَّبُورِ وَ قُلْتُ إِنَّ النَّاسَ يَذْكُرُونَ أَنَّ الشَّمَالَ مِنَ الْجَنَّةِ وَ الْجَنُوبَ مِنَ النَّارِ فَقَالَ إِنَّ لِلَّهِ عَزَّ وَ جَلَّ جُنُوداً مِنْ رِيَاحٍ يُعَذِّبُ بِهَا مَنْ يَشَاءُ مِمَّنْ عَصَاهُ وَ لِكُلِّ رِيحٍ مِنْهَا مَلَكٌ مُوَكَّلٌ بِهَا فَإِذَا أَرَادَ اللَّهُ عَزَّ وَ جَلَّ أَنْ يُعَذِّبَ قَوْماً بِنَوْعٍ مِنَ الْعَذَابِ أَوْحَى إِلَى الْمَلَكِ الْمُوَكَّلِ بِذَلِكَ النَّوْعِ مِنَ الرِّيحِ الَّتِي يُرِيدُ أَنْ يُعَذِّبَهُمْ بِهَا قَالَ فَيَأْمُرُهَا الْمَلَكُ فَيَهِيجُ كَمَا يَهِيجُ الْأَسَدُ الْمُغْضَبُ

7/57-58/2 ម្ហ្ម៉ាំម៉ាដ្ធ ប៊ិន យ៉ាស្ស៊ីយ៉ា បានរាយការណ៍តមកពី អាស្ស៊ីម៉ាដ្ធ ប៊ិន ម្ហ្ម៉ាំម៉ាដ្ធ ប៊ិន អ៊ីសា តមកពី អាល់-ហ្ហាសាន់ ប៊ិន ម៉ាស្ស៊ីប៊ុប តមកពី អ្ហ្ម៉ាលី ប៊ិន រីណាប់ និង ហ្ហ៊ីស្ស៊ាំ អ៊ីបន្ធ សាលិម តមកពី អាប៊ូ បាស្ស៊ៀর ដែលបានថាខ្ញុំបានសួរ អាប៊ូ យ៉ាកុ៌ហ្ហារ صلوات الله عليه والسلام អំពីខ្យល់បួនប្រភេទខ្យល់ជើង ខ្យល់ត្បូង អាល់-ស្ស៊ីបា និង អាល់-ដ្ធាប៊ីរ ។ ខ្ញុំបានថាគេបានថាខ្យល់ជើងមកពីឋានសួគ៌ ខ្យល់ត្បូង មកពីឋាននរក ។" ព្រះអង្គ صلوات الله عليه والسلام មានវចន:ថា៖ "អល់ឡោះហ្ស៊ូ عز وجل មានទ័ពខ្យល់ ។ ព្រះអង្គ عز وجل ដាក់ទណ្ឌកម្មអ្នកណាដែលប្រឆាំងព្រះអង្គ عز وجل ដោយខ្យល់នោះស្រេចតែព្រះអង្គ عز وجل ។ ខ្យល់នីមួយ១សុទ្ធតែមានទេវតាមួយអង្គគ្រប់គ្រងវា ។ ប្រសិនបើអល់ឡោះហ្ស៊ូ عز وجل មានព្រះបំណងដាក់ទណ្ឌកម្មប្រជារាស្ត្រណាមួយដោយទណ្ឌកម្មបែបណាមួយ ព្រះអង្គ عز وجل នឹងបើកឲ្យទេវតាដែលគ្រប់គ្រងខ្យល់ប្រភេទពិសេសនោះជ្រាប ឲ្យទៅដាក់ទណ្ឌកម្មប្រជារាស្ត្រដែលព្រះអង្គ عز وجل ទ្រង់មានព្រះបំណងធ្វើទណ្ឌកម្មដោយខ្យល់នោះ ។ ទេវតានឹងបញ្ជូនវា វានឹងជ្រួលខ្លាំងដូច រាជសីជ្រួលពេលត្រូវគេរំខាន ។"

[...] قَالَ وَ لِلَّهِ عَزَّ ذِكْرُهُ رِيَاحُ رَحْمَةٍ لَوَاقِحُ وَ غَيْرُ ذَلِكَ يَنْشُرُهَا بَيْنَ يَدَيْ رَحْمَتِهِ مِنْهَا مَا يُهَيِّجُ السَّحَابَ لِلْمَطَرِ وَ مِنْهَا رِيَاحٌ تَحْبِسُ السَّحَابَ بَيْنَ السَّمَاءِ وَ الْأَرْضِ وَ رِيَاحٌ تَعْصِرُ السَّحَابَ فَتَمْطُرُهُ بِإِذْنِ اللَّهِ وَ مِنْهَا رِيَاحٌ مِمَّا عَدَّدَ اللَّهُ فِي الْكِتَابِ. (الكافي : الجزء ٨ الصفحة ٩١ الحديث ٦٣)

ព្រះអង្គ صلوات الله عليه والسلام មានវចន:ថា៖ "អល់ឡោះហ្ស៊ូ عز ذكره មានខ្យល់ដែលប្រកបដោយព្រះមេត្តាធម៌និងខ្យល់ផ្សេងទៀតដែលព្រះអង្គ عز وجل បង្ហាញឲ្យឃើញនូវព្រះមេត្តាធម៌របស់ព្រះអង្គ عز وجل ។ មានខ្យល់ធ្វើឲ្យភ្លៀង មានខ្យល់ទ្រពពកនៅចន្លោះមេឃនិងដី មានខ្យល់គាបពពកធ្វើឲ្យមានភ្លៀងអាស្រ័យការអនុញ្ញាតរបស់អល់ឡោះហ្ស៊ូ عز وجل ហើយមានខ្យល់ដែលអល់ឡោះហ្ស៊ូ عز وجل ចែងនៅក្នុងព្រះគម្ពីរព្រះអង្គ عز وجل ។

30:45-53, 51:38-47, 54:17-21, 2:266, 89:5-13, 69:1-8 (الكافي 8: 91/ 63)

***

٧/٥٧–٣/٥٨* [المناقب] قَالَ عَمْرُو بْنُ الْعَاصِ لِلْحُسَيْنِ عَلَيْهِ السَّلاَمُ: يَا اِبْنَ عَلِيٍّ، مَا بَالُ أَوْلاَدِنَا أَكْثَرُ مِنْ أَوْلاَدِكُمْ؟! فَقَالَ عَلَيْهِ

السَّلاَمُ: بُغَاثُ اَلطَّيْرِ أَكْثَرُهَا فِرَاخاً وَ أُمَّ اَلصَّقْرِ مِقْلاَةٌ نَزُورٌ.
*7/57-58/3 អាល់-ម៉ាណាគ្ងីប ។ អ៊ុំរ៉ូ ប៊ិន អាល់-អ៊ុស្ម៉ូ បានទូល អាល់-ហ្ជ្រ៊ីសៃន ﷺ ថា៖ "ព្រះរាជបុត្រ ﷺ អ៊ុលី ﷺ អើយ! ហេតុអ្វីកូនយើងច្រើនជាងព្រះរាជបុត្ត ﷺ របស់ព្រះអង្គ ﷺ ?" ព្រះអង្គ ﷺ មានវចន:ថា៖ "សត្វស្លាបដែលខ្សោយជាងគេមានកូនច្រើន ។ មេស្ទាំងមានកូនមួយឬពុំមានកូន ។"

فَقَالَ: مَا بَالُ اَلشَّيْبِ إِلَى شَوَارِبِنَا أَسْرَعُ مِنْهُ فِي شَوَارِبِكُمْ؟ فَقَالَ عَلَيْهِ السَّلاَمُ: إِنَّ نِسَاءَكُمْ نِسَاءٌ بَجَرَةٌ، فَإِذَا دَنَا أَحَدُكُمْ مِنْ اِمْرَأَتِهِ نَكَهَتْ فِي وَجْهِهِ فَيَشِيبُ مِنْهُ شَارِبُهُ.
លោកបានទូលថា៖ "ហេតុអ្វីពុកមាត់យើងឆាប់ស្លូវជាងពុកមាត់ព្រះអង្គ ﷺ ?" ព្រះអង្គ ﷺ មានវចន:ថា៖ "បណ្ដាស្ត្រីរបស់អស់លោកមានខ្យល់ដកដង្ហើមក្ដៅ ។ ដូច្នេះពេលអស់លោកទៅកៀរភរិយាខ្លួន នាងដកដង្ហើមដាក់មុខស្វាមីខ្លួន ។ ដូច្នេះពុកមាត់អ្នកនោះទៅជាស្លូវ ។"

فَقَالَ: مَا بَالُ لِحَاكُمْ أَوْفَرُ مِنْ لِحَانَا؟! فَقَالَ عَلَيْهِ السَّلاَمُ: ﴿وَ اَلْبَلَدُ اَلطَّيِّبُ يَخْرُجُ نَبَاتُهُ بِإِذْنِ رَبِّهِ وَ اَلَّذِي خَبُثَ لاَ يَخْرُجُ إِلاَّ نَكِداً﴾
លោកបានទូលថា៖ "ហេតុអ្វីពុកចង្កាយើងសម្បូរជាងពុកមាត់យើង ?" ព្រះអង្គ ﷺ មានវចន:ថា៖ *"[៧:៥៨] តំបន់ល្អរុក្ខជាតិដុះឡើងអាស្រ័យការអនុញ្ញាតរបស់ម្ចាស់វា ។ រីឯតំបន់អាក្រក់មានរុក្ខជាតិដុះចេញមកដោយកម្រ ។"*

فَقَالَ مُعَاوِيَةُ: بِحَقِّي عَلَيْكَ إِلاَّ سَكَتَّ، فَإِنَّهُ اِبْنُ عَلِيِّ بْنِ أَبِي طَالِبٍ! فَقَالَ عَلَيْهِ السَّلاَمُ: إِنْ عَادَتِ اَلْعَقْرَبُ عُدْنَا لَهَا وَ كَانَتِ اَلنَّعْلُ لَهَا حَاضِرَةً قَدْ عَلِمَ اَلْعَقْرَبُ وَ اِسْتَيْقَنَتْ أَنْ لاَ لَهَا دُنْيَا وَ لاَ آخِرَةٌ . (المناقب ج٤ ص٦٧ ، بحار الأنوار ج٤٤ ص٢٠٩ ح٥)
មូអ៊ាវីយ៉ាស៊ុ៎ថា៖ "នេះគឺសិទ្ធិរបស់ខ្ញុំលើលោក លើកលែងតែលោកបិទមាត់ ពីព្រោះព្រះអង្គ ﷺ ជាព្រះរាជបុត្ររបស់ អ៊ុលី ﷺ ប៊ិន អាប៊ូ ត្ប៊ីលិប ﷺ ។" ព្រះអង្គ ﷺ មានវចន:ថា៖ "បើខ្យាដំរីត្រឡប់មករកយើង យើង ﷺ នឹងត្រឡប់មករកវា ស្បែកនៅចាំវា (ដើម្បីវាយកម្ទេចវា) ។ ខ្យាដំរីដឹងស្រាប់ហើយថាពិតជាពុំមានលោកនេះនិងលោកមុខសម្រាប់វាទេ ។" (المناقب 2: 67 ، بحار الأنوار 44: 209/ 5)

لَقَدْ أَرْسَلْنَا نُوحًا إِلَىٰ قَوْمِهِۦ فَقَالَ يَٰقَوْمِ ٱعْبُدُوا۟ ٱللَّهَ مَا لَكُم مِّنْ إِلَٰهٍ غَيْرُهُۥٓ إِنِّىٓ أَخَافُ عَلَيْكُمْ عَذَابَ يَوْمٍ عَظِيمٍ ﴿٥٩﴾
៥៩. យើងបានបញ្ជូននុះហ៊ូ ទៅរកប្រជាជាតិគេ គេបាន[ប្រាប់ពួកគេ]ថា៖ "ប្រជារាស្ត្រអើយ! ចូរអស់លោកធ្វើសក្តារអល់ឡោះហ៊ូ ។ អស់លោកពុំមានព្រះផ្សេងពីព្រះអង្គទេ ។ [បើអស់លោកមិនគោរពតាមព្រះសិក្ខាបទព្រះអង្គទេ] ខ្ញុំខ្លាចតែអស់លោករងព្រះទណ្ឌកម្មថ្ងៃធ្ងន់មហិមា ។"

قَالَ ٱلْمَلَأُ مِن قَوْمِهِۦٓ إِنَّا لَنَرَىٰكَ فِى ضَلَٰلٍ مُّبِينٍ ﴿٦٠﴾
៦០. ពួកមេអ្នកដឹកនាំ[ពួកបដិសេធសទ្ធា]របស់ប្រជាជាតិគេបានថា៖ "យើងឃើញថាលោកនៅក្នុងកំហុសច្បាស់ៗ"

قَالَ يَٰقَوْمِ لَيْسَ بِى ضَلَٰلَةٌ وَلَٰكِنِّى رَسُولٌ مِّن رَّبِّ ٱلْعَٰلَمِينَ ﴿٦١﴾

៦១. គេ (គឺនុះហ្ស៊ា) បានថា៖ "ប្រជារាស្ត្រអើយ! ខ្ញុំមិននៅក្នុងកំហុសទេ តែខ្ញុំជាព្រះសាសន:ទូតរបស់ម្ចាស់ពិភពទាំងពួង ។

أُبَلِّغُكُمْ رِسَٰلَٰتِ رَبِّي وَأَنصَحُ لَكُمْ وَأَعْلَمُ مِنَ ٱللَّهِ مَا لَا تَعْلَمُونَ ﴿٦٢﴾

៦២. ខ្ញុំនាំព្រះរាជសាររបស់ម្ចាស់ខ្ញុំមកឲ្យអស់លោក ។ ខ្ញុំណែនាំអស់លោក ខ្ញុំដឹងមកពីអល់ឡោះហ្ស៊ានូវអ្វីដែលអស់លោកមិនដឹង (គឺដឹងអំពីវង្វាន់របស់ព្រះអង្គ ។ ល ។) ។

أَوَعَجِبْتُمْ أَن جَآءَكُمْ ذِكْرٌ مِّن رَّبِّكُمْ عَلَىٰ رَجُلٍ مِّنكُمْ لِيُنذِرَكُمْ وَلِتَتَّقُواْ وَلَعَلَّكُمْ تُرْحَمُونَ ﴿٦٣﴾

៦៣. អស់លោកភ្ញាក់ផ្អើលឬដែលមានព្រះក្រឹនរំឭកមកពីម្ចាស់របស់អស់លោក មកដល់អស់លោកតាមរយ:បុរសម្នាក់[ដែលត្រូវជ្រើសរើស]ក្នុងបណ្តាអស់លោក ដើម្បីដាស់តឿនអស់លោកឲ្យអស់លោកខ្លាចក្រែង ក្រែងលោអស់លោកទទួលបាននូវព្រះមេត្តាធម៌[របស់អល់ឡោះហ្ស៊ា] ?"

فَكَذَّبُوهُ فَأَنجَيْنَٰهُ وَٱلَّذِينَ مَعَهُۥ فِى ٱلْفُلْكِ وَأَغْرَقْنَا ٱلَّذِينَ كَذَّبُواْ بِـَٔايَٰتِنَآ ۚ إِنَّهُمْ كَانُواْ قَوْمًا عَمِينَ ﴿٦٤﴾

៦៤. តែពួកគេបែរជាប្រមាថថាគេភ្ញាក់ផ្អើល ។ ដូច្នេះយើងបានសង្គ្រោះគេនិងបណ្តាអ្នកដែលនៅជាមួយគេក្នុងនាវា យើងបានពន្លង់ជនដែលប្រមាថព្រះសញ្ញា[និងឱ្យការ]យើង ។ ពួកគេជាប្រជាជាតិខ្វាក់ ។

អធិប្បាយអាយ៉ាស់ ៥៩-៦៤

٧/٥٩-١/٦٤ حَدَّثَنَا أَحْمَدُ بْنُ زِيَادِ بْنِ جَعْفَرٍ اَلْهَمَدَانِيُّ رَضِيَ اَللَّهُ عَنْهُ قَالَ: حَدَّثَنَا عَلِيُّ بْنُ إِبْرَاهِيمَ بْنِ هَاشِمٍ، عَنْ أَبِيهِ، عَنْ عَبْدِ اَلسَّلاَمِ بْنِ صَالِحٍ اَلْهَرَوِيِّ، عَنِ اَلرِّضَا عَلَيْهِ السَّلاَمُ قَالَ: قُلْتُ لَهُ لِأَيِّ عِلَّةٍ أَغْرَقَ اَللَّهُ عَزَّ وَ جَلَّ اَلدُّنْيَا كُلَّهَا فِي زَمَنِ نُوحٍ عَلَيْهِ السَّلاَمُ، وَ فِيهِمُ اَلْأَطْفَالُ وَ مَنْ لاَ ذَنْبَ لَهُ؟

7/59-64/1 រាយការណ៍មកពីលោក (គឺអ៊ីបនូ បាប៊ូវ៉ៃហ្ស៊ា) [...] តមកពី អ្ចាប់ឌុល សាឡាម ប៊ិន ស្ម៊ីលិះហ្ស៊ា អាល់-ហ្ការី ដែលបានថាខ្ញុំបានទូល អាល់-រ៉ីដ្ធ៊ីؤ صلوات الله عليه والسلام ថា៖ "ហេតុអ្វីអល់ឡោះហ្ស៊ាﷻបានពន្លង់លោកទាំងមូលក្នុងសម័យនុះហ្ស៊ា នៅក្នុងចំណោមពួកគេនោះមានកូនក្មេងនិងជនដែលមិនមានបាបទេ ?"

فَقَالَ: مَا كَانَ فِيهِمُ اَلْأَطْفَالُ، لِأَنَّ اَللَّهَ عَزَّ وَ جَلَّ أَعْقَمَ أَصْلاَبَ قَوْمِ نُوحٍ وَ أَرْحَامَ نِسَائِهِمْ أَرْبَعِينَ عَاماً، فَانْقَطَعَ نَسْلُهُمْ، فَغَرِقُوا وَ لاَ طِفْلَ فِيهِمْ، مَا كَانَ اَللَّهُ تَعَالَى لِيَهْلِكَ بِعَذَابِهِ مَنْ لاَ ذَنْبَ لَهُ. وَ أَمَّا اَلْبَاقُونَ مِنْ قَوْمِ نُوحٍ عَلَيْهِ السَّلاَمُ فَأُغْرِقُوا لِتَكْذِيبِهِمْ لِنَبِيِّ اَللَّهِ نُوحٍ عَلَيْهِ السَّلاَمُ، وَ سَائِرُهُمْ أُغْرِقُوا بِرِضَاهُمْ تَكْذِيبَ اَلْمُكَذِّبِينَ، وَ مَنْ غَابَ عَنْ أَمْرٍ فَرَضِيَ بِهِ كَانَ كَمَنْ شَاهَدَهُ وَ أَتَاهُ. (علل الشرائع: الجزء 1 صفحة 30)

ព្រះអង្គصلوات الله عليه والسلام មានវចន:ថា៖ "មិនមានកូនក្មេងនៅក្នុងចំណោមពួកគេទេ ពីព្រោះអល់ឡោះហ្ស៊ាﷻបានធ្វើវញ្ញកម្មទៅលើឆ្អឹងខ្នងនិងស្បូនប្រជាជាតិរបស់នុះហ្ស៊ា (គឺមិនឲ្យមានកូនបាន) អស់រយ:ពេលសែសិបឆ្នាំ ។ ដូច្នេះពួកគេមិនមានកូនចៅទេ ។ ពួកគេបានលង់ទឹកហើយមិនមានកូនក្មេងនៅក្នុងចំណោមពួកគេទេ ។ អល់ឡោះហ្ស៊ាﷻមិនកម្ទេចដោយទណ្ឌកម្មព្រះអង្គﷻបុគ្គលដែលមិនមានបាបនោះទេ ។ ប្រជាជាតិនុះហ្ស៊ាដែលនៅសេសសល់ ព្រះអង្គﷻបានពន្លង់ពួកគេព្រោះពួកគេបានប្រឆាំងតតាំងនុះហ្ស៊ា ព្រះសាស្តាអល់ឡោះហ្ស៊ាﷻ ។ រីឯអ្នកឯទៀតក្នុងចំណោមពួកគេនោះត្រូវពន្លង់ព្រោះពួកគេគាប់ចិត្តនឹងការប្រឆាំងតតាំងរបស់ពួកអ្នកប្រឆាំង ។ បុគ្គលណាដែលអវត្តមានក្នុងរឿងអ្វីមួយតែគាប់ចិត្តនឹង

រឿងនោះ បុគ្គលរូបនោះដូចបុគ្គលដែលមានវត្តមានហើយបានចូលរួមក្នុងរឿងនោះដែរ ។"

26:104-121 (علل الشرائع: 30/ 1)

***

*٧/٥٩-٦٤/٢ عَلِيُّ بْنُ إِبْرَاهِيمَ عَنْ أَبِيهِ عَنِ ابْنِ مَحْبُوبٍ عَنْ هِشَامٍ الْخُرَاسَانِيِّ عَنِ الْمُفَضَّلِ بْنِ عُمَرَ قَالَ كُنْتُ عِنْدَ أَبِي عَبْدِ اللَّهِ (عليه السلام) بِالْكُوفَةِ أَيَّامَ قَدِمَ عَلَى أَبِي الْعَبَّاسِ فَلَمَّا انْتَهَيْنَا إِلَى الْكُنَاسَةِ قَالَ هَاهُنَا صُلِبَ عَمِّي زَيْدٌ رَحِمَهُ اللَّهُ ثُمَّ مَضَى حَتَّى انْتَهَى إِلَى طَاقِ الزَّيَّاتِينَ وَ هُوَ آخِرُ السَّرَّاجِينَ فَنَزَلَ وَ قَالَ انْزِلْ فَإِنَّ هَذَا الْمَوْضِعَ كَانَ مَسْجِدَ الْكُوفَةِ الْأَوَّلَ الَّذِي خَطَّهُ آدَمُ (عليه السلام) وَ أَنَا أَكْرَهُ أَنْ أَدْخُلَهُ رَاكِباً قَالَ قُلْتُ فَمَنْ غَيَّرَهُ عَنْ خِطَّتِهِ قَالَ أَمَّا أَوَّلُ ذَلِكَ الطُّوفَانُ فِي زَمَنِ نُوحٍ (عليه السلام) ثُمَّ غَيَّرَهُ أَصْحَابُ كِسْرَى وَ نُعْمَانَ ثُمَّ غَيَّرَهُ بَعْدُ زِيَادُ بْنُ أَبِي سُفْيَانَ

*7/59-64/2 អ្ន៉លី ប៊ិន អ៊ីបរ៉ហ៊ីមបានតំណាលតមកពីឪពុកលោក [...] តមកពីអាល់-មូហ្ហាដ្ជ៉ូដ្ជ៉ល់ ប៊ិន អ៊ីម៉ារដែលបានតំណាលថាខ្ញុំបាននៅជុំជាមួយអាប៊ូ អ្ន៉ប់ឌ្ឈុលឡោះហ្ស៊ីតាអាឡា នៅឯការបាឡាអ៊ីក្នុងសម័យ អ្ន៉លី ប៊ិន អាល់-អ្ន៉ប់បាស់ ។ ពេលយើងឈប់នៅឯអាល់-គូណាសាសុ ព្រះអង្គ ﷺ មានវចន:ថា៖ "គេបានចងឆ្កាងស្ទ្ឍ ឪពុកមាខ្ញុំ ﷺ នៅត្រង់នេះ ។ សូមអល់ឡោះហ្ស៊ីតាអាឡាអាណិតអាសូរលោក ។" បន្ទាប់មកយើងបានធ្វើដំណើរទៅមុខទៀត លុះបានទៅដល់រានអ្នកលក់ប្រេង នៅចុងបំផុតនៃចង្កៀងពីរ ។ ព្រះអង្គ ﷺ បានចុះដីហើយមានវចន:ថា៖ "ចុះមក ព្រោះទីនេះគឺកន្លែងដំបូងបង្អ្ន ស់របស់ម៉ាស់ជ្ជិដ្ជ អាល់-គូហ្ហាសុ ដែលអ្ន ដ្ជ ាំ ﷺ បានដៅ ។ ខ្ញុំ ﷺ មិនចូលចិត្តចូលមកកាន់ទីនេះដោយជិះជំនិះទេ ។" ខ្ញុំ បានទូលថា៖ "អ្នកណាម្ន ាក់ទៀតដែលបានដៅកន្លែងម៉ាស់ជ្ជិដ្ជនេះ ?" ព្រះអង្គ ﷺ មានវចន:ថា៖ "ដំបូងគឺព្យ ុះសង្ឃ ្ឍ ក្នុងសម័យនុ ះហ ូ ﷺ ។ បន្ទាប់មកគឺបក្ស ពួ ករបស់គិសរ (كِسْرَى chosroes) និងនុ ម៉ ូ ម ាន បន្ទ ាប់ពីនោ ះគ ឺ ស ្ ស ីយ ា ដ ុ ំ ប ិ ន អ ា ប ូ ស ុ ហ ្ ហ យ ា ន ។"

